វិទ្យាល័យហ៊ុនសែនអន្គប្រីយ៍

លំហាត់គណិតវិទ្យា

សម្រាប់ត្រៀមប្រឡងសិស្សពូកែ
និង ប្រឡងប្រជែងនានា

កម្រិតសិស្សវិទ្យាល័យ



ភាគ ៣

$$R=\sqrt{\frac{(R_1R_4+R_2R_3)(R_1R_2+R_3R_4)}{R_1R_3+R_2R_4}}$$

រៀបរៀងដោយៈ

អ៊ឹម ឈុនហោ និង អ៊ី គឹមឃឿន

ស្រាវជ្រាវ និង រៀបរៀង

លោក **អ៊ឹម ឈុនហោ** និង លោក **អ៊ុំ គឹមឃឿន**

ត្រួតពិនិត្យបច្ចេកទេស

លោក **អយ ស៊ីណា** សាស្ត្រាចារ្យគណិតវិទ្យានៃវិ.ហាសអង្គរបុរី

លោក **គិត កញ្ញា** សាស្ត្រាចារ្យគណិតវិទ្យានៃវិ.ពួក(សៀមរាប)

យុវសិស្ស **ស៊ឹម ទិច្ឆិកា** ជ័យលាភីសិស្សពូកែទូទាំងខេត្តតាកែវ

ផ្នែកគណិតវិទ្យាថ្នាក់ទី**១២** ចំណាត់ថ្នាក់លេខ **៣** ឆ្នាំ ២០១៦

យុវសិស្ស **ស៊ិន រិទ្ធី** ជ័យលាភីសិស្សពូកែទូទាំងខេត្តតាកែវ

ផ្នែកគណិតវិទ្យាថ្នាក់ទី**១២** ចំណាត់ថ្នាក់លេខ **៥** ឆ្នាំ ២០១៦

យុវសិស្ស **សឹម សាន់ឌី** ជ័យលាភីសិស្សពូកែទូទាំងខេត្តតាកែវ

ផ្នែកគណិតវិទ្យាថ្នាក់ទី**៩** ចំណាត់ថ្នាក់លេខ **២** ឆ្នាំ ២០១៤

និងចំណាត់ថ្នាក់លេខ **១** ថ្នាក់ទី**១២** ឆ្នាំ ២០១៧

ត្រួតពិនិត្យអក្ខរាវិរុទ្ធ

យុវសិស្ស **ជា សេងលី** រៀននៅវិទ្យាល័យអង្គព្រះស្តេច

យុវសិស្ស **ទ្រី ហ៊ិចហួយ** រៀននៅវិទ្យាល័យអង្គព្រះស្តេច

វាយអត្ថបទ

លោក **អ៊ឹម ឈុនហោ**សាស្ត្រាចារ្យគណិតវិទ្យានៃវិ.ហាសអង្គប្រីយ៍

លោក **អ៊ុំ គឹមឃឿន** ជ័យលាភីសិស្សពូកែទូទាំង ខេត្តតាកែវ

ផ្នែកគណិតវិទ្យាថ្នាក់ទី**១២** ចំណាត់ថ្នាក់លេខ **២** ឆ្នាំ ២០១៥

រចនាក្រប

លោក **អ៊ឹម ឈុនហោ**សាស្ត្រាចារ្យគណិតវិទ្យានៃវិ.ហាសអង្គប្រីយ៍

អារម្ភកថា

សៀវភៅ **លំហាត់គណិតវិទ្យា ភាគ ៣** សម្រាប់ត្រៀមប្រឡងសិស្សពូកែដែលអ្នកសិក្សាកំពុងកាន់នៅក្នុងដៃនេះ យើងខ្ញុំបានខិតខំស្រាវជ្រាវ និងរៀបរៀងឡើងក្នុងគោលបំណងទុកជាឯកសារ សម្រាប់ជាជំនួយដល់អ្នកសិក្សា ជាពិសេសសម្រាប់សិស្សដែលមានបំណងចង់ប្រឡងសិស្សពូកែផ្នែកគណិតវិទ្យាកម្រិតមធ្យមសិក្សាទុតិយភូមិ នាពេលដ៏ខ្លីខាងមុខ ។

សៀវភៅនេះផងដែរ យើងខ្ញុំបានដកស្រង់លំហាត់ចេញពីសៀវភៅបរទេសខ្លះ អ៊ិនធើណិតខ្លះនិងខ្លះទៀតជាលំហាត់ដែលធ្លាប់ចេញប្រលងសិស្សពូកែក្នុងប្រទេស និងក្រៅប្រទេស ។

ទោះបីជាយើងខ្ញុំជាអ្នករៀបរៀង ក៏ដូចជាអ្នកត្រួតពិនិត្យខិតខំពិនិត្យដោយយកចិត្តទុកដាក់យ៉ាងណា ក៏ដោយ កង្វះខាត និងកំហុសឆ្គងដោយអចេតនាប្រាកដជាមាន ។

អាស្រ័យហេតុនេះយើងខ្ញុំរង់ចាំដោយរីករាយជានិច្ចនូវមតិរិះគន់ពីគ្រប់មជ្ឈដ្ឋានដើម្បីស្ថាបនានិងកែលម្អសៀវភៅនេះឲ្យកាន់តែប្រសើរថែមទៀត ។

ជាទីបញ្ចប់យើងខ្ញុំសូមគោរពជូនពរដល់អ្នកសិក្សាទាំងអស់ឲ្យមានសុខភាពល្អនិងសម្រេចបានដូចអ្វីដែលប៉ងប្រាថ្នាទៅថ្ងៃមុខ ៕

តាកែវ ថ្ងៃទី ២១ មិថុនា ២០១៧

អ្នករៀបរៀង

អ៊ឹម ឈុនហោ និង អ៊ី គីមឃឿន

ផ្នែកទី១ រូបមន្តសង្ខេបសំខាន់ៗ

❖ វិសមភាពមួយចំនួន

១_វិសមភាពមធ្យម *(Mean inequalities)*

បើ $a_1, a_2, ..., a_n$ ជាចំនួនពិតវិជ្ជមាននោះគេបាន:

$$QM = \sqrt{\frac{a_1^2 + a_2^2 + \cdots + a_n^2}{n}} \qquad AM = \frac{a_1 + a_2 + \cdots + a_n}{n}$$

$$GM = \sqrt[n]{a_1 a_2 ... a_n} \qquad HM = \frac{n}{\frac{1}{a_1} + \frac{1}{a_2} + \cdots + \frac{1}{a_n}}$$

វិសមភាព $AM - GM$ គឺ $\frac{a_1 + a_2 + \cdots + a_n}{n} \geq \sqrt[n]{a_1 a_2 ... a_n}$

វិសមភាព $AM - HM$ គឺ $\frac{a_1 + a_2 + \cdots + a_n}{n} \geq \frac{n}{\frac{1}{a_1} + \frac{1}{a_2} + \cdots + \frac{1}{a_n}}$

វិសមភាព $AM - QM$ គឺ $\frac{a_1 + a_2 + \cdots + a_n}{n} \geq \sqrt{\frac{a_1^2 + a_2^2 + \cdots + a_n^2}{n}}$

សមភាពកើតមានកាលណា $a_1 = a_2 = \cdots = a_n$

២_វិសមភាពកូស៊ីស្វា *(Cauchy-Schwarz inequalities)*

_បើ $a_1, a_2, \cdots, a_n$; $b_1, b_2, \cdots, b_n$ ជាចំនួនពិតគេបាន:

$$\left(\sum_{i=1}^{n} a_i^2\right)\left(\sum_{i=1}^{n} b_i^2\right) \geq \left(\sum_{i=1}^{n} a_i b_i\right)^2 \quad \text{ឬ} \quad \left|\sum_{i=1}^{n} a_i b_i\right| \leq \sqrt{\left(\sum_{i=1}^{n} a_i^2\right)\left(\sum_{i}^{n} b_i^2\right)}$$

_បើ $a_1, a_2, \cdots, a_n$; $b_1, b_2, \cdots, b_n$ ជាចំនួនពិតនិង $b_1, b_2, \cdots, b_n > 0$ នោះ

$$\frac{a_1^2}{b_1}+\frac{a_2^2}{b_2}+\cdots+\frac{a_n^2}{b_n}\geq\frac{(a_1+a_1+\cdots+a_n)^2}{b_1+b_2+\cdots+b_n}$$

សមភាពកើតមានកាលណា $\frac{a_1}{b_1}=\frac{a_2}{b_2}=\cdots=\frac{a_n}{b_n}$

៣_វិសមភាព *Chebishev*

បើ $a_1\leq a_2\leq\ldots\leq a_n$ និង $b_1\leq b_2\leq\ldots\leq b_n$ គេបាន:

$$\left(\sum_{i=1}^{n}a_i\right)\left(\sum_{i=1}^{n}b_i\right)\leq n\sum_{i=1}^{n}a_ib_i$$

សមភាពកើតមានកាលណា $a_1=a_2=\cdots=a_n$ ឬ $b_1=b_2=\cdots=b_n$

៤_វិសមភាព *Holder*

បើ $a_1,a_2,\cdots,a_n\ ;\ b_1,b_2,\cdots,b_n$ ជាចំនួនពិតវិជ្ជមាននិង $p,q>1$

$\frac{1}{p}+\frac{1}{q}=1$ គេបាន: $\sum_{i=1}^{n}a_ib_i\leq\left(\sum_{i=1}^{n}a_i^p\right)^{\frac{1}{p}}\left(\sum_{i=1}^{n}b_i^q\right)^{\frac{1}{q}}$

សមភាពកើតមានកាលណា $\frac{a_1^p}{b_1^q}=\frac{a_2^p}{b_2^q}=\cdots=\frac{a_n^p}{b_n^q}$

៥_វិសមភាព *Bernoulli*

គេឲ្យ $a>-1$ និង $n\in\mathbb{Q}^+$

បើ $n\geq1$ នោះ $(1+a)^n\geq1+na$ សមភាពកើតមានពេល $a=0$ ឬ $n=1$

បើ $0<n<1$ នោះ $(1+a)^n<1+na$

៦_វិសមភាព *Jensen*

គេមានអនុគមន៍ $f(x)$ កំណត់លើចន្លោះ (a,b) ។

ឧបមាថា $f''(x)<0$ លើចន្លោះ $(a\ ,\ b)$

និង $\forall x_1 , x_2 ,....,x_n \in (a , b) ; \forall n \geq 2$ យើងបាន:

$$\frac{f(x_1)+f(x_2)+....+f(x_n)}{n} \leq f\left(\frac{x_1+x_2+....+x_n}{n}\right)$$

ឧបមាថា $f''(x)>0$ លើចន្លោះ (a , b) និង

$\forall x_1 , x_2 ,....,x_n \in (a , b) ; \forall n \geq 2$ យើងបាន:

$$\frac{f(x_1)+f(x_2)+....+f(x_n)}{n} \geq f\left(\frac{x_1+x_2+....+x_n}{n}\right)$$

វិសមភាពទាំងពីរខាងលើក្លាយជាសមភាពនៅពេល $x_1 = x_2 = ... = x_n$

៧_វិសមភាព *Minkowski*

បើ $a_1,a_2,\cdots,a_n$; $b_1,b_2,\cdots,b_n$ និង $c_1,c_2,\cdots,c_n$ ជាចំនួនពិតគេបាន:

$$\sqrt{a_1^2+b_1^2+c_1^2}+\sqrt{a_2^2+b_2^2+c_2^2}+....+\sqrt{a_n^2+b_n^2+c_n^2}$$
$$\geq \sqrt{(a_1+b_1+c_1)^2+(a_2+b_2+c_2)^2+....+(a_n+b_n+c_n)^2}$$

❖រូបមន្តសំខាន់មួយចំនួន

១_ក្រឡាផ្ទៃត្រីកោណ

①បើត្រីកោណ *ABC* មានជ្រុង a,b,c និងកម្ពស់ h_a,h_b,h_b គេបាន:

ក្រឡាផ្ទៃត្រីកោណ $S=\frac{1}{2}ah_a=\frac{1}{2}bh_b=\frac{1}{2}ch_c$

$$S=\frac{1}{2}bc\sin A=\frac{1}{2}ac\sin B=\frac{1}{2}ab\sin C$$

②បើត្រីកោណ *ABC* មានជ្រុង a,b,c និង $p=\frac{a+b+c}{2}$ កន្លះបរិមាត្រ

ក្រឡាផ្ទៃត្រីកោណ $S=\sqrt{p(p-a)(p-b)(p-c)}$ **(រូបមន្តហេរ៉ុង)**

③គេឲ្យត្រីកោណ *ABC* មានជ្រុង a,b,c និង p កន្លះបរិមាត្រ ។

បើ r ជាកាំរង្វង់ចារឹកក្នុងនិង R ជាកាំរង្វង់ចារឹកក្រៅត្រីកោណនោះ

ក្រឡាផ្ទៃត្រីកោណ $S = pr = \dfrac{abc}{4R}$ ។

២_ក្រឡាផ្ទៃចតុកោណចារឹកក្នុងរង្វង់

បើចតុកោណ $ABCD$ មានជ្រុង a,b,c,d ចារឹកក្នុងរង្វង់ និង p កន្លះបរិមាត្រនោះក្រឡាផ្ទៃចតុកោណកំណត់ដោយ:

$S = \sqrt{(p-a)(p-b)(p-c)(p-d)}$ ដែល $p = \dfrac{a+b+c+d}{2}$ ។

៣_ក្រឡាផ្ទៃចតុកោណប៉ោង

គេឲ្យចតុកោណប៉ោង $ABCD$ មានជ្រុង a,b,c,d និងកន្លះបរិមាត្រនោះក្រឡាផ្ទៃរបស់វាកំណត់ដោយ:

$S = \sqrt{(p-a)(p-b)(p-c)(p-d) - abcd\cos^2\dfrac{A+C}{2}}$ ។

៤_កន្សោម $\sin\dfrac{A}{2}$, $\cos\dfrac{A}{2}$, $\tan\dfrac{A}{2}$

គេឲ្យត្រីកោណ ABC មានជ្រុង a,b,c និង p កន្លះបរិមាត្រគេបាន

$\sin\dfrac{A}{2} = \sqrt{\dfrac{(p-b)(p-c)}{bc}}$

$\cos\dfrac{A}{2} = \sqrt{\dfrac{p(p-a)}{bc}}$ រូបមន្តលំនាំគ្នាចំពោះមុំ $\dfrac{B}{2}$ និង $\dfrac{C}{2}$ ។

$\tan\dfrac{A}{2} = \sqrt{\dfrac{(p-b)(p-c)}{p(p-a)}}$

៥_រូបមន្តកាំរង្វង់ចារឹកក្នុងត្រីកោណ

បើត្រីកោណ ABC មានជ្រុង a,b,c និង $p = \dfrac{a+b+c}{2}$ កន្លះបរិមាត្រ ហើយ r ជាកាំរង្វង់ចារឹកក្នុងត្រីកោណនោះគេបាន:

$r = (p-a)\tan\dfrac{A}{2} = (p-b)\tan\dfrac{B}{2} = (p-c)\tan\dfrac{C}{2}$

$$r=\frac{a\sin\frac{B}{2}\sin\frac{C}{2}}{\cos\frac{A}{2}}=\frac{b\sin\frac{A}{2}\sin\frac{C}{2}}{\cos\frac{B}{2}}=\frac{c\sin\frac{A}{2}\sin\frac{B}{2}}{\cos\frac{C}{2}}$$ ។

៦_រូបមន្តកាំរង្វង់ចារឹកក្នុងមុំមួយនៃត្រីកោណ

គេឲ្យត្រីកោណ ABC មានជ្រុង a,b,c និង p កន្លះបរិមាត្រ ។
បើ r_a ជាកាំរង្វង់ចារឹកក្នុងមុំ A នៃត្រីកោណ ABC គេបាន:

$$r_a=p\tan\frac{A}{2}=\frac{a\cos\frac{B}{2}\cos\frac{C}{2}}{\cos\frac{A}{2}}=\frac{p-c}{\tan\frac{B}{2}}=\frac{p-b}{\tan\frac{C}{2}}$$ ។

រូបមន្តលំនាំគ្នាចំពោះ r_b, r_c និង ។

៧_ចម្ងាយពីផ្ចិតរង្វង់ចារឹកក្នុងត្រីកោណទៅកំពូលត្រីកោណ

គេឲ្យត្រីកោណ ABC មានជ្រុង a,b,c ។ បើ I ជាផ្ចិតរង្វង់ចារឹកក្នុង នៃត្រីកោណនោះគេបាន:

$$IA=\sqrt{\frac{p-a}{p}\cdot bc}\qquad IB=\sqrt{\frac{p-b}{p}\cdot ac}\qquad IC=\sqrt{\frac{p-c}{p}\cdot ab}$$ ។

៨_ចម្ងាយពីផ្ចិតរង្វង់ចារឹកក្នុងទៅផ្ចិតរង្វង់ចារឹកក្រៅត្រីកោណ(រូបមន្តអឺលែ)

គេឲ្យត្រីកោណ ABC មាន I ជាផ្ចិតរង្វង់ចារឹកក្នុងត្រីកោណ និង O ជាផ្ចិតរង្វង់ចារឹកក្រៅត្រីកោណ ។ បើ r និង R ជាកាំរង្វង់ចារឹកក្នុង និងក្រៅត្រីកោណនោះ គេបាន: $OI=\sqrt{R(R-2r)}$ ។



❖ទ្រឹស្តីបទមួយចំនួន

១_ទ្រឹស្តីបទស៊ីនុស

បើ ABC ជាត្រីកោណមានជ្រុង a,b,c ចារឹកក្នុងរង្វង់ផ្ចិត O កាំ R

គេបាន: $\dfrac{a}{\sin A}=\dfrac{b}{\sin B}=\dfrac{c}{\sin C}=2R$ ។

២_ទ្រឹស្តីបទកូស៊ីនុស

បើ ABC ជាត្រីកោណមួយមានជ្រុង $BC=a, AC=b, AB=c$

គេបាន: $a^2=b^2+c^2-2bc\cos A$

$$b^2=a^2+c^2-2ac\cos B$$

$$c^2=a^2+b^2-2ab\cos C$$

៣_រូបមន្តចំណោលកែង

បើ ABC ជាត្រីកោណមួយមានជ្រុង $BC=a, AC=b, AB=c$

គេបាន: $a=b\cos C+c\cos B$

$$b=c\cos A+a\cos C$$

$$c=a\cos B+b\cos A$$

៤_ទ្រឹស្តីបទមេដ្យាន

បើ ABC ជាត្រីកោណមួយមាន m_a, m_b, m_c ជាមេដ្យានត្រូវគ្នានឹង ជ្រុង a,b,c គេបាន: $4m_a^2=2b^2+2c^2-a^2$

$$4m_b^2=2a^2+2c^2-b^2$$

$$4m_c^2=2a^2+2b^2-c^2$$

៥_ទ្រឹស្តីបទកន្លះបន្ទាត់ពុះមុំ

គេឲ្យ ABC ជាត្រីកោណមានជ្រុង a,b,c និង l_a, l_b, l_c ជាកន្លះបន្ទាត់ពុះមុំក្នុង A,B,C រៀងគ្នា នោះគេបាន:

$$l_a=\frac{2bc}{b+c}\cos\frac{A}{2}=\frac{2}{b+c}\sqrt{pbc(p-a)}$$

$$l_b=\frac{2ac}{a+c}\cos\frac{B}{2}=\frac{2}{a+c}\sqrt{pac(p-b)}$$

$$l_c=\frac{2ab}{a+b}\cos\frac{C}{2}=\frac{2}{a+b}\sqrt{pab(p-c)}$$

៦_ទ្រឹស្តីបទកន្លះបន្ទាត់ពុះមុំ

បើ AM ជាកន្លះបន្ទាត់ពុះមុំ A ក្នុង ត្រីកោណ ABC គេបាន:

$\frac{BM}{MC}=\frac{AB}{AC}$ ។



៧_ទ្រឹស្តីបទសេវ៉ា $(Ceva's\ theorem)$

ក្នុងត្រីកោណ ABC មួយមានបន្ទាត់បី AD, BE, CF ប្រសព្វគ្នា ត្រង់ចំណុច I មួយលុះត្រាតែ $\frac{AF}{FB}\cdot\frac{BD}{DC}\cdot\frac{CE}{EA}=1$ ។



៨_ទ្រឹស្តីបទមីនីឡូស *(Menelaus's theorem)*

តាមរូបចំណុចទី៧ ABD ជាត្រីកោណ បើចំណុច F, I, C រត់ត្រង់គ្នា នោះគេបាន: $\frac{AF}{FB}\cdot\frac{BC}{CD}\cdot\frac{DI}{IA}=1$

៩_ទ្រឹស្តីបទតូលេមី $(Ptolemy's\ theorem)$



បើ $ABCD$ ជាចតុកោណចារឹកក្នុងរង្វង់
និង AC, BD ជាអង្កត់ទ្រូង គេបាន:

$AC.BD = AB.CD + BC.AD$ ។

១០_វិសមភាពតូលេមី ($Ptolemy's\ inequality$)

បើ $ABCD$ ជាចតុកោណចារឹកក្នុងរង្វង់
និង AC, BD ជាអង្កត់ទ្រូង គេបាន:

$AB.CD + BC.AD \ge AC.BD$ ។

១១_ទ្រឹស្តីបទឡាយបនិច ($Leibniz's\ theorem$)

គេឲ្យ ABC ជាត្រីកោណមានជ្រុង a,b,c ហើយ O ជាផ្ចិតរង្វង់
ចារឹកក្នុង G ជាទីប្រជុំទម្ងន់នៃត្រីកោណគេបាន:

$$OG^2 = R^2 - \frac{a^2+b^2+c^2}{9}$$ ។

១២_ទ្រឹស្តីបទ $Stewart$ ($Stewart's\ theorem$)

គេឲ្យ ABC ជាត្រីកោណមានជ្រុង a,b,c ។
P ជាចំណុចមួយនៅលើ AB
ដែល $PA=m$, $PB=n$
និង $m+n=c$ ។ គេបាន:

$ma^2+nb^2=(m+n)PC^2+mn^2+nm^2$



១៣_ទ្រឹស្តីបទ $Euler$ ($Euler's\ theorem$)

បើ $ABCD$ ជាចតុកោណចារឹក
ក្នុងរង្វង់និង AC, BD ជាអង្កត់
ទ្រូង បើ E កណ្តាល BD និង F
កណ្តាល AC គេបាន:



$$AB^2+BC^2+CD^2+DA^2=AC^2+BD^2+4EF^2$$

❖រូបមន្តអនុគមន៍ត្រីកោណមាត្រ

១_រូបមន្តផលបូក និងផលដក

$$\bullet\sin(\alpha+\beta)=\sin\alpha\cos\beta+\sin\beta\cos\alpha$$

$$\bullet\sin(\alpha-\beta)=\sin\alpha\cos\beta-\sin\beta\cos\alpha$$

$$\bullet\cos(\alpha+\beta)=\cos\alpha\cos\beta-\sin\alpha\sin\beta$$

$$\bullet\cos(\alpha-\beta)=\cos\alpha\cos\beta+\sin\alpha\sin\beta$$

$$\bullet\tan(\alpha+\beta)=\frac{\tan\alpha+\tan\beta}{1-\tan\alpha\tan\beta} \qquad \bullet\tan(\alpha-\beta)=\frac{\tan\alpha-\tan\beta}{1+\tan\alpha\tan\beta}$$

$$\bullet\cot(\alpha+\beta)=\frac{\cot\alpha\cot\beta-1}{\cot\alpha+\cot\beta} \qquad \bullet\cot(\alpha-\beta)=\frac{\cot\alpha\cot\beta+1}{\cot\alpha-\cot\beta}$$

២_រូបមន្តមុំឌុប

$$\bullet\sin 2\alpha=2\sin\alpha\cos\alpha \qquad \bullet\cos 2\alpha=\cos^2\alpha-\sin^2\alpha=2\cos^2\alpha-1$$

$$\bullet\tan 2\alpha=\frac{2\tan\alpha}{1-\tan^2\alpha} \qquad \bullet\cot 2\alpha=\frac{\cot^2\alpha-1}{2\cot\alpha} \quad , \quad =1-2\sin^2\alpha$$

៣_រូបមន្តកន្លះមុំ

$$\bullet\sin^2\frac{\alpha}{2}=\frac{1-\cos\alpha}{2} \qquad \bullet\sin\alpha=2\sin\frac{\alpha}{2}\cos\frac{\alpha}{2}$$

$$\bullet\cos^2\alpha=\frac{1+\cos\alpha}{2} \qquad \bullet\tan^2\frac{\alpha}{2}=\frac{1-\cos\alpha}{1+\cos\alpha}$$

៤_កន្សោម $\sin\alpha$, $\cos\alpha$, $\tan\alpha$ ជាអនុគមន៍ $t=\tan\frac{\alpha}{2}$

$$\bullet\sin\alpha=\frac{2t}{1+t^2} \qquad \bullet\cos\alpha=\frac{1-t^2}{1+t^2} \qquad \bullet\tan\alpha=\frac{2t}{1-t^2}$$

៥_កន្សោមមុំ 3α , 4α និង 5α

$$\bullet \sin 3\alpha = 3\sin\alpha - 4\sin^3\alpha = 4\sin x \sin\left(\frac{\pi}{3} - x\right)\sin\left(\frac{\pi}{3} + x\right)$$

$$\bullet \cos 3\alpha = 4\cos^3\alpha - 3\cos\alpha = 4\cos x\cos\left(\frac{\pi}{3} - x\right)\cos\left(\frac{\pi}{3} + x\right)$$

$$\bullet \tan 3\alpha = \frac{3\tan\alpha - \tan^3\alpha}{1 - 3\tan^2\alpha} = \tan x\tan\left(\frac{\pi}{3} - x\right)\tan\left(\frac{\pi}{3} + x\right)$$

$$\bullet \cot 3\alpha = \frac{3\cot\alpha - \cot^3\alpha}{1 - 3\cot^2\alpha} = \cot x\cot\left(\frac{\pi}{3} - x\right)\cot\left(\frac{\pi}{3} + x\right)$$

$$\bullet \sin 4\alpha = 4\sin\alpha\cos\alpha - 8\sin^3\alpha\cos\alpha$$

$$\bullet \cos 4\alpha = 8\cos^4\alpha - 8\cos^2\alpha + 1$$

$$\bullet \tan 4\alpha = \frac{4\tan\alpha - 3\tan^3\alpha}{1 - 6\tan^2\alpha + \tan^4\alpha}$$

$$\bullet \sin 5\alpha = 16\sin^5\alpha - 20\sin^3\alpha + 5\sin\alpha$$

$$\bullet \cos 5\alpha = 16\cos^5\alpha - 20\cos^3\alpha + 5\cos\alpha$$

$$\bullet \tan 5\alpha = \frac{\tan^5\alpha - 10\tan^3\alpha + 5\tan\alpha}{1 - \tan^2\alpha + 5\tan^4\alpha}$$

៦_រូបមន្តបម្លែងពីផលគុណទៅផលបូក

$$\bullet \cos\alpha\cos\beta = \frac{1}{2}\left[\cos(\alpha+\beta) + \cos(\alpha-\beta)\right]$$

$$\bullet \sin\alpha\sin\beta = \frac{1}{2}\left[\cos(\alpha-\beta) - \cos(\alpha+\beta)\right]$$

$$\bullet \sin\alpha\cos\beta = \frac{1}{2}\left[\sin(\alpha+\beta) + \sin(\alpha-\beta)\right]$$

$$\bullet \sin\beta\cos\alpha = \frac{1}{2}\left[\sin(\alpha+\beta) - \sin(\alpha-\beta)\right]$$

៧_រូបមន្តបម្លែងពីផលបូកទៅផលគុណ

$\bullet \cos p+\cos q=2\cos\frac{p+q}{2}\cos\frac{p-q}{2}$

$\bullet \tan p+\tan q=\frac{\sin(p+q)}{\cos p\cos q}$

$\bullet \cos p-\cos q=-2\sin\frac{p+q}{2}\sin\frac{p-q}{2}$

$\bullet \tan p-\tan q=\frac{\sin(p-q)}{\cos p\cos q}$

$\bullet \sin p+\sin q=2\sin\frac{p+q}{2}\cos\frac{p-q}{2}$

$\bullet \cot p+\cot q=\frac{\sin(p+q)}{\sin p\sin q}$

$\bullet \sin p-\sin q=2\sin\frac{p-q}{2}\cos\frac{p+q}{2}$

$\bullet \cot p-\cot q=\frac{\sin(q-p)}{\sin p\sin q}$

$\bullet \tan(a+b+c)=\frac{\tan a+\tan b+\tan c-\tan a\tan b\tan c}{1-\tan a\tan b-\tan b\tan c-\tan c\tan a}$

៨_សមីការត្រីកោណមាត្រ

- សមីការ $\sin x=\sin\alpha \Leftrightarrow \left[\begin{array}{l} x=\alpha+2k\pi \\ x=\pi-\alpha+2k\pi \quad , \quad k\in\mathbb{Z}\end{array}\right.$
- សមីការ $\sin u(x)=\sin v(x) \Leftrightarrow \left[\begin{array}{l} u(x)=v(x)+2k\pi \\ u(x)=\pi-v(x)+2k\pi \quad , \quad k\in\mathbb{Z}\end{array}\right.$
- សមីការ $\cos x=\cos\alpha \Leftrightarrow \left[\begin{array}{l} x=\alpha+2k\pi \\ x=-\alpha+2k\pi \quad , \quad k\in\mathbb{Z}\end{array}\right.$
- សមីការ $\cos u(x)=\cos v(x) \Leftrightarrow \left[\begin{array}{l} u(x)=v(x)+2k\pi \\ u(x)=-v(x)+2k\pi \quad , \quad k\in\mathbb{Z}\end{array}\right.$
- សមីការ $\tan x=\tan\alpha \Leftrightarrow x=\alpha+k\pi \quad , \quad k\in\mathbb{Z}$
- សមីការ $\tan u(x)=\tan v(x) \Leftrightarrow u(x)=v(x)+k\pi \quad , \quad k\in\mathbb{Z}$
- សមីការ $\cot x=\cot\alpha \Leftrightarrow x=\alpha+k\pi \quad , \quad k\in\mathbb{Z}$
- សមីការ $\cot u(x)=\cot v(x) \Leftrightarrow u(x)=v(x)+k\pi \quad , \quad k\in\mathbb{Z}$

❖ សមភាពអនុគមន៍ត្រីកោណមាត្រមួយចំនួនៈ

បើ α,β,γ ជាមុំក្នុងត្រីកោណមួយគេបានសមភាពដូចខាងក្រោមៈ

1/ $\cos\alpha+\cos\beta+\cos\gamma=1+4\sin\frac{\alpha}{2}\sin\frac{\beta}{2}\sin\frac{\gamma}{2}$

$2/\sin\alpha+\sin\beta+\sin\gamma=4\cos\frac{\alpha}{2}\cos\frac{\beta}{2}\cos\frac{\gamma}{2}$

$3/\sin 2\alpha+\sin 2\beta+\sin 2\gamma=4\sin\alpha\sin\beta\sin\gamma$

$4/\sin^2\alpha+\sin^2\beta+\sin^2\gamma=2+2\cos\alpha\cos\beta\cos\gamma$

$5/\sin^2\frac{\alpha}{2}+\sin^2\frac{\beta}{2}+\sin^2\frac{\gamma}{2}+2\sin\frac{\alpha}{2}\sin\frac{\beta}{2}\sin\frac{\gamma}{2}=1$

$6/\tan\frac{\alpha}{2}\tan\frac{\beta}{2}+\tan\frac{\beta}{2}\tan\frac{\gamma}{2}+\tan\frac{\gamma}{2}\tan\frac{\alpha}{2}=1$

$7/\tan\alpha+\tan\beta+\tan\gamma=\tan\alpha\tan\beta\tan\gamma$

$8/\cot\frac{\alpha}{2}+\cot\frac{\beta}{2}+\cot\frac{\gamma}{2}=\cot\frac{\alpha}{2}\cot\frac{\beta}{2}\cot\frac{\gamma}{2}$

❖ វិសមភាពអនុគមន៍ត្រីកោណមាត្រមួយចំនួនៈ

$1/\sin\alpha+\sin\beta+\sin\gamma\le\frac{3\sqrt{3}}{2}$

$2/\sin\alpha\sin\beta\sin\gamma\le\frac{3\sqrt{3}}{8}$

$3/\sin\frac{\alpha}{2}\sin\frac{\beta}{2}\sin\frac{\gamma}{2}\le\frac{1}{8}$

$4/\sin\frac{\alpha}{2}+\sin\frac{\beta}{2}+\sin\frac{\gamma}{2}\le\frac{3}{2}$

$5/\cos\alpha+\cos\beta+\cos\gamma\le\frac{3}{2}$

$6/\cos\alpha\cos\beta\cos\gamma\le\frac{1}{8}$

$7/\cos\frac{\alpha}{2}+\cos\frac{\beta}{2}+\cos\frac{\gamma}{2}\le\frac{3\sqrt{3}}{2}$

$8/\cos\frac{\alpha}{2}\cos\frac{\beta}{2}\cos\frac{\gamma}{2}\le\frac{3\sqrt{3}}{8}$

$9/\sin^2\alpha+\sin^2\beta+\sin^2\gamma\le\frac{9}{4}$

$10/\sin^2\frac{\alpha}{2}+\sin^2\frac{\beta}{2}+\sin^2\frac{\beta}{2}\ge\frac{3}{4}$

$11/\cos^2\alpha+\cos^2\beta+\cos^2\gamma\ge\frac{3}{4}$

$12/\cos^2\frac{\alpha}{2}+\cos^2\frac{\beta}{2}+\cos^2\frac{\beta}{2}\le\frac{9}{4}$

$13/\tan\frac{\alpha}{2}+\tan\frac{\beta}{2}+\tan\frac{\gamma}{2}\ge\sqrt{3}$

$14/\cot\frac{\alpha}{2}+\cot\frac{\beta}{2}+\cot\frac{\beta}{2}\ge 3\sqrt{3}$

ផ្នែកទី២ ប្រធានលំហាត់

លំហាត់ទី១

គេឲ្យស្វ៊ីតនព្វន្ត $\alpha_1,\alpha_2,...,\alpha_{45}$ ដែលមានតួទី 1 គឺ $\alpha_1=1^o$ និង ផលសងរួម $d=4^o$ ។ ស្រាយបញ្ជាក់ថា $\sum_{i=1}^{45}\tan\alpha_i=45$ ។

លំហាត់ទី២

គេឲ្យ $k\in\mathbb{N}$ និង $a_1,a_2,\ldots,a_n$ ជាចំនួនពិតវិជ្ជមានដែលផ្ទៀងផ្ទាត់ថា: $a_1+a_2+\cdots+a_n=1$ ។ ស្រាយថា: $a_1^{-k}+a_2^{-k}+\cdots+a_n^{-k}\ge n^{k+1}$ ។

លំហាត់ទី៣

គេឲ្យស្វ៊ីតនៃចំនួនពិតកំណត់ដោយ $A=\{a_1,a_2,a_3,\ldots\}$ ។ កំណត់យក ΔA ជាស្វ៊ីតដែល $\Delta A=\{a_2-a_1,a_3-a_2,a_4-a_3,\ldots\}$ សន្មតថាគ្រប់តួនៃស្វ៊ីត $\Delta(\Delta A)$ គឺ 1 ដែល $a_{19}=a_{92}=0$ ។ រក a_1

លំហាត់ទី៤

គេឲ្យស្វ៊ីត *Fibonacci* មួយកំណត់ដោយ: $f_1=f_2=1$ និង $f_{n+2}=f_{n+1}+f_n\ (n\in\mathbb{N})$ ។ ស្រាយថា: $f_{2n}=\dfrac{f_{2n+2}^3+f_{2n-2}^3}{9}-2f_{2n}^3$ ចំពោះគ្រប់ $n\ge 2$ ។

លំហាត់ទី៥

ដោះស្រាយសមីការ: $2^x+3^x-4^x+6^x-9^x=1$

លំហាត់ទី៦

គណនាតម្លៃនៃកន្សោម: $A=\sum_{k=0}^{n}\binom{n}{k}k^2$ ។

លំហាត់ទី៧

គេឲ្យ $\frac{a}{bc-a^2}+\frac{b}{ac-b^2}+\frac{c}{ab-c^2}=0$ ។ ស្រាយថា:

$\frac{a}{(bc-a^2)^2}+\frac{b}{(ac-b^2)^2}+\frac{c}{(ab-c^2)^2}=0$ ។

លំហាត់ទី៨

គេឲ្យ a,b ជាការេនៃពីរចំនួនគត់សេសវិជ្ជមានតគ្នា។

ស្រាយថា: $ab-a-b+1 \vdots 192$ ។

លំហាត់ទី៩

រកចំនួន $\overline{xyz}$ ដែលផ្ទៀងផ្ទាត់ថា: $\overline{xyz}+\overline{xzy}=\overline{zzz}$ ។

លំហាត់ទី១០

ស្រាយថា: $7^{9^{9^{9^9}}}-7^{9^9} \vdots 100$ ។

លំហាត់ទី១១

គេឲ្យស្វ៊ីត (u_n) កំណត់ដោយ: $u_0=u_1=u_2=1$ និង

$\det\begin{pmatrix} u_{n+3} & u_{n+2} \\ u_{n+1} & u_n \end{pmatrix}=n!\,, n\geq 0$ ។

ស្រាយថាគ្រប់តួនៃស្វ៊ីត (u_n) ជាចំនួន គត់ចំពោះគ្រប់ n ។

លំហាត់ទី១២

រកតួទូទៅនៃស្វ៊ីត (T_n) ដែលកំណត់ដោយ: $T_1, T_n=T_{\sqrt{n}}+c\log_2 n$

ហើយ c ជាចំនួនថេរ ។

លំហាត់ទី១៣

គេឲ្យត្រីកោណ ABC មួយស្រាយថា:

$\sin^3 A\sin(B-C)+\sin^3 B\sin(C-A)+\sin^3 C\sin(A-B)=0$

លំហាត់ទី១៤

គេឲ្យ $x,y,z\geq 0$ ដែល $x+y+z=6$ រកតម្លៃតូចបំផុតនៃកន្សោម:

$S=\frac{2015}{7+3\ln(x+1)-y}+\frac{2015}{7+3\ln(y+1)-z}+\frac{2015}{7+3\ln(z+1)-z}$ ។

លំហាត់ទី១៥

គេឲ្យត្រីកោណ ABC មួយស្រាយថា:

$$\frac{a\sin A+b\sin B+c\sin C}{a\cos A+b\cos B+c\cos C}=\cot A+\cot B+\cot C$$ ។

លំហាត់ទី១៦

គេឲ្យត្រីកោណ ABC មួយស្រាយថា:

$$(a-b)\tan\frac{A}{2}\tan\frac{B}{2}+(b-c)\tan\frac{B}{2}\tan\frac{C}{2}+(c-a)\tan\frac{C}{2}\tan\frac{A}{2}=0$$ ។

លំហាត់ទី១៧

គេឲ្យ a,b,c ជាចំនួនពិតវិជ្ជមាន ។ ស្រាយថា:

$$\sqrt{\frac{a+b}{c}}+\sqrt{\frac{b+c}{a}}+\sqrt{\frac{c+a}{b}}\ge 3\sqrt{2}$$ ។

លំហាត់ទី១៨

គេឲ្យ $\sin x+\sin y=a$ និង $\cos x+\cos y=b$ ។ គណនាតម្លៃនៃ $\tan\frac{x}{2}$ និង $\tan\frac{y}{2}$ ជាអនុគមន៍នៃ a,b ។

លំហាត់ទី១៩

គេឲ្យអនុគមន៍ដែលកំណត់ដោយ $g(t)=t^p-t$ ស្រាយថា $g(x+a)\equiv g(x)\pmod p$ ចំពោះគ្រប់ចំនួនគត់វិជ្ជមាន a ។

លំហាត់ទី២០

គណនាផលបូក:

$$S=2.1^2C_{2015}^1+3.2^2C_{2015}^2+4.3^2C_{2015}^3+\cdots+2016.2015^2C_{2015}^{2015}$$ ។

លំហាត់ទី២១

រកតម្លៃធំបំផុតនៃកន្សោម: $A_{2015}=\sum_{k=0}^{2015}(k-2015x)^2x^kC_{2015}^k(1-x)^{2015-k}$

បើ $x\in[0,1]$ ។

លំហាត់ទី២២

គេឲ្យ $S_n = a^n + b^n + c^n$ ដែល $n \in \mathbb{Z}$ ។ ស្រាយថា:

$$6S_{n+3} = 6S_1S_{n+2} - 3(S_1^2 - S_2)S_{n+1} + (S_1^3 - 3S_1S_2 + 2S_3)S_n$$ ។

លំហាត់ទី២៣

គេឲ្យ a, b, c ជាចំនួនពិតដែលផ្ទៀងផ្ទាត់ថា: $2a^2 + 3b^2 + 7c^2 = 1$ រកតម្លៃធំបំផុតនៃអនុគមន៍ $f(a,b,c) = 2013a - 2014b + 2015c$ ។

លំហាត់ទី២៤

គេឲ្យ $a_1, a_2, \ldots, a_n$ ជាចំនួនពិតដែលផ្ទៀងផ្ទាត់ $a_1 + a_2 + \cdots + a_n \geq n^2$ និង $a_1^2 + a_2^2 + \cdots + a_n^2 \leq n^3 + 1$ ។ ស្រាយថា: $n - 1 \leq a_k \leq n + 1$ ចំពោះគ្រប់ចំនួនគត់វិជ្ជមាន $k \leq n$ ។

លំហាត់ទី២៥

គេឲ្យ x_1, x_2, x_3 ជាឫសនៃសមីការ $x^3 + ax^2 + x + b = 0, (b \neq 0)$ ។

ស្រាយថា:

$$\left(x_1 - \frac{1}{x_1}\right)\left(x_2 - \frac{1}{x_2}\right) + \left(x_2 - \frac{1}{x_2}\right)\left(x_3 - \frac{1}{x_3}\right) + \left(x_3 - \frac{1}{x_3}\right)\left(x_1 - \frac{1}{x_1}\right) = 4$$

លំហាត់ទី២៦

គេឲ្យត្រីកោណ ABC មួយ។ស្រាយបញ្ជាក់សមភាពខាងក្រោម:

$$\frac{1}{\sin A} + \frac{1}{\sin B} + \frac{1}{\sin C} = \frac{1}{2}\left(\tan\frac{A}{2} + \tan\frac{B}{2} + \tan\frac{C}{2} + \cot\frac{A}{2}\cot\frac{B}{2}\cot\frac{C}{2}\right)$$

លំហាត់ទី២៧

ស្រាយបញ្ជាក់សមភាព: $\tan\frac{3\pi}{11} + 4\sin\frac{2\pi}{11} = \sqrt{11}$ ។

លំហាត់ទី២៨

គេឲ្យស្វ៊ីត $(Febonacci)$ កំណត់ដោយ: $F_1 = F_2 = 1$ និង

$F_{n+1}=F_n+F_{n-1}, n\geq 2$ ស្រាយថា: $F_n=\frac{1}{\sqrt{5}}\left[\left(\frac{1+\sqrt{5}}{2}\right)^n-\left(\frac{1-\sqrt{5}}{2}\right)^n\right]$

លំហាត់ទី២៩

គេឲ្យស្វ៊ីត $(Febonacci)$ កំណត់ដោយ: $F_1=F_2=1$ និង

$F_{n+1}=F_n+F_{n-1}, n\geq 2$ ស្រាយថា: $F_{n-1}F_{n+1}=F_n^2+(-1)^n$ ។

លំហាត់ទី៣០

គេឲ្យស្វ៊ីត $(Febonacci)$ កំណត់ដោយ: $F_1=F_2=1$ និង

$F_{n+1}=F_n+F_{n-1}, n\geq 2$ ស្រាយថា: $F_{m+n+1}=F_{n+1}F_{m+1}+F_mF_n \ , m\in\mathbb{N}$

លំហាត់ទី៣១

គេឲ្យស្វ៊ីត $(Febonacci)$ កំណត់ដោយ: $F_1=F_2=1$ និង

$F_{n+1}=F_n+F_{n-1}, n\geq 2$ ស្រាយថាចំពោះគ្រប់ n,k ជាចំនួនគត់

ធម្មជាតិនោះប្រភាគ $\frac{kF_{n+2}+F_n}{kF_{n+3}+F_{n+1}}$ សម្រួលមិនបាន ។

លំហាត់ទី៣២

គេឲ្យស្វ៊ីត $(Febonacci)$ កំណត់ដោយ: $F_1=F_2=1$ និង

$F_{n+1}=F_n+F_{n-1}, n\geq 2$ ស្រាយថា: $F_1+F_2+\cdots+F_n=F_{n+2}-1$ ។

លំហាត់ទី៣៣

គេឲ្យស្វ៊ីត $(Febonacci)$ កំណត់ដោយ: $F_1=F_2=1$ និង

$F_n=F_{n-1}+F_{n-2}, n\geq 3$ ។ តាង $Q=\begin{pmatrix}1&1\\1&0\end{pmatrix}$ ស្រាយថា:

$Q^n=\begin{pmatrix}F_{n+1}&F_n\\F_n&F_{n-1}\end{pmatrix}, n\geq 2$ រួចទាញថា: $F_{3n}=F_{n+1}^3+F_n^3-F_{n-1}^3 \ , n\geq 1$

លំហាត់ទី៣៤

គេឲ្យស្វ៊ីត $(Febonacci)$ កំណត់ដោយ: $F_1=F_2=1$ និង

$F_{n+1}=F_n+F_{n-1}, n\geq 2$ ស្រាយថាបញ្ជាក់ថា: $F_{2n}=F_{n+1}^2-F_{n-1}^2$ ។

លំហាត់ទី៣៥

គេឲ្យស្វ៊ីត $(Febonacci)$ កំណត់ដោយ: $F_1 = F_2 = 1$ និង

$F_{n+1} = F_n + F_{n-1}, n \geq 2$ ស្រាយថា: $F_{2n}F_{n-1} - F_{2n-1}F_n = (-1)^n F_n, n \geq 1$

រួចគណនា: $\sum_{n=0}^{\infty} \frac{1}{F_{2^n}}$ ។

លំហាត់ទី៣៦

គេឲ្យ $f : \mathbb{N}^* \to \mathbb{R}$ ផ្ទៀងផ្ទាត់លក្ខខណ្ឌខាងក្រោម:

$f(n+2) = f(n+1) - f(n)$; $f(1) = 1$, $f(2) = 0$

បង្ហាញថា: $|f(n)| \leq \frac{2\sqrt{3}}{3}$, $\forall n \in \mathbb{N}^*$ ។

លំហាត់ទី៣៧

អនុគមន៍ $f : \mathbb{R} \to \mathbb{R}$ ហើយផ្ទៀងផ្ទាត់លក្ខខណ្ឌ

$f\left(x^2 + x + 3\right) + 2f\left(x^2 - 3x + 5\right) = 6x^2 - 10x + 7$, $\forall x \in \mathbb{R}$ ។

គណនា $f(2015)$ ។

លំហាត់ទី៣៨

កំណត់អនុគមន៍ f ដែលកំណត់លើសំណុំចំនួនពិតវិជ្ជមាន ឬ សូន្យ $\mathbb{R}_+$ ទៅ $\mathbb{R}_+$ ហើយផ្ទៀងផ្ទាត់លក្ខខណ្ឌ:

$(i). f(2) = 0$

$(ii). f(x) \neq 0$; $0 \leq x < 2$

$(iii). f(x.f(y)).f(y) = f(x+y)$ ចំពោះ $\forall x, y \in \mathbb{R}_+$

លំហាត់ទី៣៩

ត្រីកោណ ABC មានជ្រុង $BC = x$, $AC = y$ និង $AB = z$ ។

រកតម្លៃតូចបំផុត $S = \sqrt{\frac{x}{2y+2z-x}} + \sqrt{\frac{y}{2z+2x-y}} + \sqrt{\frac{z}{2x+2y-z}}$

លំហាត់ទី៤០

ស្រាយថា: $\sqrt[3]{\cos\frac{2\pi}{7}}+\sqrt[3]{\cos\frac{4\pi}{7}}+\sqrt[3]{\cos\frac{6\pi}{7}}=\sqrt[3]{\frac{1}{2}\left(5-3\sqrt[3]{7}\right)}$

លំហាត់ទី៤១

គេឲ្យត្រីកោណ ABC មួយចារឹកក្នុងរង្វង់កាំ $R=1$ និងមានជ្រុង $BC=a$, $AC=b$, $AB=c$ ហើយ មុំ A , B , C បង្កើតបានជាស្វ៊ីតធរណីមាត្រដែលមានផលធៀប

រួមស្មើ 2 ។ គណនា $a^2+b^2+c^2$ ។

លំហាត់ទី៤២

A និង B ជាចំនួនគត់វិជ្ជមានដែល:

$\frac{A}{B}=1-\frac{1}{2}+\frac{1}{3}-\frac{1}{4}+\cdots-\frac{1}{1342}+\frac{1}{1343}$ ។

បង្ហាញថា A ចែកដាច់នឹង 2015 ។

លំហាត់ទី៤៣

កំណត់ចំនួនថេរ k ដែលពហុធា:

$P(x,y,z)=x^5+y^5+z^5+k\left(x^3+y^3+z^3\right)\left(x^2+y^2+z^2\right)$ មានជាកត្តា $x+y+z$ ។ ស្រាយថាចំពោះតម្លៃ k ដែលរកឃើញនេះ

ពហុធា $P(x,y,z)$ មានជាកត្តា $(x+y+z)^2$ ។

លំហាត់ទី៤៤

ត្រីកោណ ABC មួយកែងត្រង់ A ចរឹកក្រៅរង្វង់ផ្ចិត I និងកាំ r x,y,z ជាប្រវែងពីផ្ចិតទៅកំពូល A,B,C រៀងគ្នា ។

បង្ហាញថា: $\frac{1}{x^2}=\frac{1}{y^2}+\frac{1}{z^2}+\frac{\sqrt{2}}{yz}$ ។

លំហាត់ទី៤៥

ចតុកោណប៉ោង $ABCD$ មួយមានជ្រុង $AB=a,BC=b,CD=c$ និង $DA=d$ ចារឹកក្រៅរង្វង់ផ្ចិត I ។

បង្ហាញថាក្រឡាផ្ទៃចតុកោណប៉ោង $S=\sqrt{abcd}.\sin\frac{A+C}{2}$ ។

លំហាត់ទី៤៦

ត្រីកោណ ABC មួយមានជ្រុង $BC=a$, $AC=b$, $AB=b$ ។
r និង R ជាផ្ចិតរង្វង់ចារឹកក្នុងនិងក្រៅត្រីកោណ ABC រៀងគ្នា ហើយ I ជាផ្ចិតរង្វង់ចារឹកក្នុងត្រីកោណ ។ បង្ហាញថា:

$a)\ IA.IB.IC=4Rr^2$

$b)\ aIA^2+bIB^2+bIC^2=abc$

លំហាត់ទី៤៧

ចតុកោណ $ABCD$ ចារឹកក្នុងរង្វង់ផ្ចិត O និងកាំ R ។ អង្កត់ទ្រូង AC និង BD កាត់គ្នាត្រង់ចំណុច M ។ R_1,R_2,R_3,R_4 ជាកាំរង្វង់ចារឹកក្រៅត្រីកោណ MAB,MBC,MCD និង MDA រៀងគ្នា ។

ស្រាយថា: $R=\sqrt{\frac{(R_1R_4+R_2R_3)(R_1R_2+R_3R_4)}{R_1R_3+R_2R_4}}$

លំហាត់ទី៤៨

គេឲ្យ α,β,φ ជាមុំបីវិជ្ជមានផ្ទៀងផ្ទាត់ $\alpha+\beta+\varphi=\frac{\pi}{2}$ ។

រកតម្លៃធំបំផុតនៃ:

$P=\sqrt{1+\tan\alpha\tan\beta}+\sqrt{1+\tan\beta\tan\varphi}+\sqrt{1+\tan\varphi\tan\alpha}$

លំហាត់ទី៤៩

ត្រីកោណ ABC មួយមានជ្រុង $BC=a,AC=b,AB=c$ ផ្ទៀងផ្ទាត់ $bc\sqrt{3}=R[2(b+c)-a]$ ។ R ជាកាំរង្វង់ចារឹកក្រៅត្រីកោណ ។ បង្ហាញថា ABC ជាត្រីកោណសម័ង្ស ។

លំហាត់ទី៥០

កំណាត់អនុគមន៍ $y=f(x)$ ផ្ទៀងផ្ទាត់លក្ខខណ្ឌ:

$f(xy)+f(x-y)+f(x+y+1)=xy+2x+1\ ;\ \forall x,y\in\mathbb{R}$

លំហាត់ទី៥១

គេមានអនុគមន៍ពីរ $f(x)=\sqrt[3]{\frac{x}{2}+\sqrt{\frac{x^2}{4}-1}}+\sqrt[3]{\frac{x}{2}-\sqrt{\frac{x^2}{4}-1}}$

$$g(x)=x^4-4x^2+2$$

បង្ហាញថា $f[g(x)]=g[f(x)]$ ចំពោះគ្រប់ $\forall x\geq 2$ ។

លំហាត់ទី៥២

កំណត់គ្រប់អនុគមន៍ $f:\mathbb{R}\to\mathbb{R}$ ផ្ទៀងផ្ទាត់លក្ខខណ្ឌ:

$f(x).f(y)-f(x+y)=\sin x.\sin y$ ។

លំហាត់ទី៥៣

ស្រាយថាគ្រប់អនុគមន៍ $f:\mathbb{R}\to\mathbb{R}$ ដែលផ្ទៀងផ្ទាត់លក្ខខណ្ឌ:

$\forall x,y\in\mathbb{R}: f(xy+x+y)=f(xy)+f(x)+f(y)$ លុះត្រាតែ

$\forall x,y\in\mathbb{R}: f(x+y)=f(x)+f(y)$

លំហាត់ទី៥៤

រកឫសជាចំនួនគត់របស់សមីការ:

$1/\ x^2+2015x+2016y^2+y=xy+2016xy^2+2017$

$2/\ x^4+2014x^3+1014049x^2+x-\sqrt{2x+2015}+1008=0$

លំហាត់ទី៥៥

ដោះស្រាយសមីការខាងក្រោម:

$1/\log_{2+\sqrt{3}}\left(\sqrt{x^2+1}+x\right)^2+\log_{2-\sqrt{3}}\left(\sqrt{x^2+1}-x\right)=6$

$2/\log_{2016}\left(\sqrt{1+x^2}+x\right)=\log_{2015}\left(\sqrt{1+x^2}-x\right)$

លំហាត់ទី៥៦

ស្រាយបញ្ជាក់ថាចំពោះគ្រប់ចំនួនពិតវិជ្ជមាន a,b,c គេបាន:

$$\left(a^2+b^2+c^2\right)\left(\frac{1}{a+b}+\frac{1}{b+c}+\frac{1}{c+a}\right)\ge\frac{3}{2}(a+b+c)$$

លំហាត់ទី៥៧

គេឲ្យស្វ៊ីតនៃចំនួនពិតវិជ្ជមាន (x_n) និង (y_n) ផ្ទៀងផ្ទាត់

លក្ខខណ្ឌ $x_1=y_1=\dfrac{1}{\sqrt{2}}$ និង $\begin{cases} x_{n+1}=\dfrac{x_n}{4y_{n+1}^2-1} \ ; \ \forall n=1,2,\ldots \\ y_{n+1}=\dfrac{y_n}{1-4x_{n+1}^2} \ ; \ \forall n=1,2,\ldots \end{cases}$

ក) ស្រាយបញ្ជាក់ថា: $x_n^2+y_n^2=1 \ , \ \forall n=1,2,\ldots$

ខ) គណនាលីមីត $\lim\limits_{n\to+\infty}x_n$ និង $\lim\limits_{n\to+\infty}y_n$ ។

លំហាត់ទី៥៨

គេឲ្យ $p\,,q\,,r$ ជាចំនួនសនិទានមិនសូន្យដែល

$\sqrt[3]{pq^2}+\sqrt[3]{pr^2}+\sqrt[3]{rp^2}$ ជាចំនួនសនិទានមិនសូន្យ ។

ស្រាយបញ្ជាក់ថា: $\dfrac{1}{\sqrt[3]{pq^2}}+\dfrac{1}{\sqrt[3]{qr^2}}+\dfrac{1}{\sqrt[3]{rp^2}}$ ក៏ជាចំនួនសនិទានដែរ

លំហាត់ទី៥៩

គេឲ្យ $k\,,l$ ជាចំនួនគត់វិជ្ជមានដែល k ចែកដាច់ l ។

ស្រាយថាចំពោះគ្រប់ចំនួនគត់វិជ្ជមាន m នោះ $1+(k+m)l$ និង

$1+ml$ ជាចំនួនបឋមរវាងគ្នា ។

លំហាត់ទី៦០

គេឲ្យ z_1,z_2,z_3 ជាចំនួនកុំផ្លិចមិនមែនជាចំនួនពិតទាំងអស់ដែល

$|z_1|=|z_2|=|z_3|$ និង $2\left(z_1+z_2+z_3\right)-3z_1z_2z_3\in\mathbb{R}$ ។

ស្រាយថា: $\max\left(\arg z_1\ ,\ \arg z_2\ ,\ \arg z_3\right)\ge\dfrac{\pi}{6}$ ។

លំហាត់ទី៦១

ចំពោះចំនួនពិត $a\,,b\,,c$ កំណត់យក $S_n=a^n+b^n+c^n$ ចំពោះគ្រប់

$n \geq 0$ បើ $S_1 = 2$, $S_2 = 6$ និង $S_3 = 14$ ។

ស្រាយបញ្ជាក់ថា $\left|S_n^2 - S_{n-1}.S_{n+1}\right| = 8$ ចំពោះគ្រប់ $n \geq 0$ ។

លំហាត់ទី៦២

ស្រាយថាចំពោះគ្រប់ចំនួនគត់វិជ្ជមាន n ជ្រុងនៃត្រីកោណ

6.10^{n+2} , $1125.10^{2n+1} - 8$, $1125.10^{2n+1} + 8$ ជាត្រីកោណកែង ។

លំហាត់ទី៦៣

ដាក់ជាផលគុណកត្តាចំពោះកន្សោមខាងក្រោម:

ក/ $(x+y+z)^5 - x^5 - y^5 - z^5$

ខ/ $(x+y)^7 - x^7 - y^7$

លំហាត់ទី៦៤

គេឲ្យ a,b,c ជាបីចំនួនគត់វិជ្ជមាន និងកំណត់ដោយ:

$x = \gcd(b,c)$; $y = \gcd(a,c)$; $z = \gcd(a,b)$ ។

ស្រាយថា: $\gcd(a,b,c) = g(x,y,z)$ ។

លំហាត់ទី៦៥

គេឲ្យ n ជាចំនួនគត់ដែល $a+b+c+d=0$ ស្រាយថា:

ផលគុណ $(bc-ad)(ac-bd)(ab-cd)$ ជាការេប្រាកដ ។

លំហាត់ទី៦៦

គេឲ្យ a,b,c,d ជាចំនួនពិតវិជ្ជមាន ស្រាយបញ្ជាក់វិសមភាព:

$$\frac{a^2+b^2+c^2}{a+b+c} + \frac{b^2+c^2+d^2}{b+c+d} + \frac{c^2+d^2+a^2}{c+d+a} + \frac{d^2+a^2+b^2}{d+a+b} \geq a+b+c+d$$

លំហាត់ទី៦៧

គេឲ្យតួទី p និង q នៃស្វ៊ីតនព្វន្តមួយគឺ q និង p រៀងគ្នា ។

គណនាតួទី $p+q$ ។

លំហាត់ទី៦៨

គេឲ្យត្រីកោណ ABC មួយ ។ នៅលើជ្រុង AB, AC និង BC យកប ណ្តាចំណុចរៀងគ្នា C_1 , B_1 និង A_1 ដែលបណ្តាអង្កត់ AA_1 , BB_1 , CC_1 កាត់គ្នាត្រង់ចំណុច M មួយ ។
ចំណុច A_2 , B_2 និង C_2 ឆ្លុះរៀងគ្នាជាមួយបណ្តាចំណុច A , B និង C ធៀបនឹងចំណុច A_1 , B_1 និង C_1 ។
ចូរស្រាយថា $S_{A_2B_2C_2} = 4S_{A_1B_1C_1} + 3S_{ABC}$ ។

លំហាត់ទី៦៩

គេឲ្យអនុគមន៍ $f(x) = x^2 - x - 2015\times 2016$ ។ ស្រាយថា $f\left(2014\sin 2013x\right)$ និង $f\left(2013\cos 2014x\right)$ ជាចំនួនអវិជ្ជមាន ។

លំហាត់ទី៧០

ABC ជាត្រីកោណមួយមាន BD ជាកន្លះបន្ទាត់ពុះមុំ B ។ រង្វង់ចារឹកក្រៅត្រីកោណ BDC កាត់ជ្រុង AB ត្រង់ E ហើយរង្វង់ចារឹកក្រៅ ត្រីកោណ ABD កាត់ជ្រុង BC ត្រង់ចំណុច F ។ បង្ហាញថា $AE = CF$ ។ *សិស្សពូកែខេត្តតាកែវ ឆ្នាំ ២០១៥*

លំហាត់ទី៧១

$ABCD$ ជាចតុកោណកែងមួយ។ E ជាចំណុចមួយនៅលើ AB (ចន្លោះ A និង B) និង F ជាចំណុចមួយនៅលើ AD (ចន្លោះ A និង D) ។ ផ្ទៃក្រឡាត្រីកោណ EBC គឺ $16m^2$ ផ្ទៃក្រឡាត្រីកោណ EAF គឺ $12m^2$ និង ផ្ទៃក្រឡាត្រីកោណ FDC គឺ $30m^2$ ។
រកផ្ទៃក្រឡានៃត្រីកោ EFC ។ *សិស្សពូកែខេត្តតាកែវ ឆ្នាំ ២០១៥*

លំហាត់ទី៧២

គេឲ្យ $A=x\sqrt{1+y^2}+y\sqrt{1+x^2}$ ។ចូរគណនាតម្លៃនៃកន្សោម A ដោយដឹងថា $xy+\sqrt{(1+x^2)(1+y^2)}=2015$ ។

លំហាត់ទី៧៣

គេឲ្យអនុគមន៍ $f_1(x)=\dfrac{1}{\sqrt[2015]{1-x^{2015}}}$ ចំពោះគ្រប់ចំនួនពិត x និង $f_n(x)=f_1\left(f_{n-1}(x)\right)$, $n\geq 2$ ។ គណនា $f_{2016}(2015)$ ។

លំហាត់ទី៧៤

គេឲ្យអនុគមន៍ $f(x)=a\sin x+b\sqrt[3]{x}+2015$ ដែល a និង b ជាពីរចំនួនពិត ។ បើ $f(\log\log_3 10)=1$ ។ គណនាតម្លៃនៃ $f(\log\log 3)$

លំហាត់ទី៧៥

ស្រាយបញ្ជាក់ថា:

$$1/\ \frac{b-c}{a}\cos^2\frac{A}{2}+\frac{c-a}{b}\cos^2\frac{B}{2}+\frac{a-b}{c}\cos^2\frac{C}{2}=0$$

$$2/\ (a-b)\cot\frac{c}{2}+(c-a)\cot\frac{B}{2}+(b-c)\cot\frac{A}{2}=0$$

$$3/\ \frac{a\sin\frac{B-C}{2}}{\sin\frac{A}{2}}+\frac{b\sin\frac{C-A}{2}}{\sin\frac{B}{2}}+\frac{c\sin\frac{A-B}{2}}{\sin\frac{C}{2}}=0$$

$$4/\ bc\cot\frac{A}{2}+ac\cot\frac{B}{2}+ab\cot\frac{C}{2}=4Rp^2\left(\frac{1}{a}+\frac{1}{b}+\frac{1}{c}-\frac{3}{p}\right)$$

$$5/\ \frac{a^2\cos\frac{B-C}{2}}{2\sin\frac{A}{2}}+\frac{b^2\cos\frac{A-C}{2}}{2\sin\frac{B}{2}}+\frac{c^2\cos\frac{A-B}{2}}{2\sin\frac{C}{2}}=ab+bc+ac$$

$$6/\ \tan\frac{A}{2}+\tan\frac{B}{2}+\tan\frac{C}{2}=\frac{4R+r}{p}$$

លំហាត់ទី៧៦

គេឲ្យចំនួនកុំផ្លិច $z=\cos\frac{2\pi}{5}+i\sin\frac{2\pi}{5}$ ហើយ S និង T ជា ចំនួនកុំផ្លិចកំណត់ដោយ: $S=z+z^2+z^4$ និង $T=z^3+z^5+z^6$ ។

១-បង្ហាញថា S មានផ្នែកនិមិត្តវិជ្ជមាន ហើយ S និង T ជាចំនួនកុំផ្លិចឆ្លាស់គ្នា ។

២-គណនា $S+T$, $S.T$ រួចរក S និង T ។

៣-បង្ហាញថា $\cos\frac{\pi}{7}-\cos\frac{2\pi}{7}+\cos\frac{3\pi}{7}=\frac{1}{2}$

និងគណនា $\sin\frac{\pi}{7}-\sin\frac{2\pi}{7}-\sin\frac{3\pi}{7}$ ។ *ខេត្តតាកែវឆ្នាំ ២០១៦*

លំហាត់ទី៧៧

គណនាផលបូក *(សិស្សពូកែខេត្តតាកែវ ឆ្នាំ ២០១៦)*

$$S=\frac{C(n,0)}{C(2n-1,0)}+\frac{C(n,1)}{C(2n-1,1)}+\frac{C(n,2)}{C(2n-1,2)}+\cdots+\frac{C(n,n)}{C(2n-1,n)}$$

លំហាត់ទី៧៨

គេឲ្យចំណុច I មួយស្ថិតនៅផ្នែកខាងក្នុងនៃត្រីកោណ ABC ។ គេដឹងថា AI , BI និង CI កាត់ជ្រុងឈម BC , CA និង AB ត្រង់ចំណុច D , E និង F រៀងគ្នា ។

ក. គណនា $\frac{BD}{DC}\cdot\frac{CE}{EA}\cdot\frac{AF}{FB}$

ខ. បង្ហាញថា $\frac{AF}{FB}+\frac{AE}{EC}=\frac{AI}{ID}$ *(សិស្សពូកែខេត្តតាកែវ ២០១៦)*

លំហាត់ទី៧៩

គេឲ្យអនុគមន៍ $f:\mathbb{N}\to\mathbb{R}$ ដែលមាន $f(1)=1$ និង

$f(1)+2f(2)+3f(3)++nf(n)=n(n+1)f(n)\quad \forall n\in\mathbb{N}\,,\, n\geq 2$ ។

គណនា $f(1008)$

លំហាត់ទី៨0

បើ $\frac{\tan x}{2}=\frac{\tan y}{3}=\frac{\tan z}{5}$ និង $x+y+z=\pi$ ។

ចូរគណនា $\tan^2 x+\tan^2 y+\tan^2 z$ ។

លំហាត់ទី៨១

n ជាចំនួនគត់ធម្មជាតិ និង $1\le n\le 100$ ។

រកចំនួនឫសនៃសមីការ $\left[\frac{n}{2}\right]+\left[\frac{n}{3}\right]+\left[\frac{n}{5}\right]=\frac{n}{2}+\frac{n}{3}+\frac{n}{5}$ ។

លំហាត់ទី៨២

សមីការ $x^5-3x^4-1=0$ មានឫសជាចំនួនកុំផ្លិចប្រាំ r_1,r_2,r_3,r_4,r_5

គណនាតម្លៃនៃ $\frac{1}{r_1^9}+\frac{1}{r_2^9}+\frac{1}{r_3^9}+\frac{1}{r_4^9}+\frac{1}{r_5^9}$ ។

លំហាត់ទី៨៣

គេឲ្យ $iz^2=1+\frac{2}{z}+\frac{3}{z^2}+\frac{4}{z^3}+\frac{5}{z^4}+\ldots$ និង $z=n\pm\sqrt{i^{-1}}$ ។

គណនាតម្លៃនៃ n ។

លំហាត់ទី៨៤

បង្ហាញថា: $1<\frac{1}{1001}+\frac{1}{1002}+\frac{1}{1003}+\ldots+\frac{1}{3001}<\frac{4}{3}$

លំហាត់ទី៨៥

បើ $\left(\frac{y}{z}\right)^a\left(\frac{z}{x}\right)^b\left(\frac{x}{y}\right)^c=1$ និង $A=\left(\frac{y}{z}\right)^{\frac{1}{b-c}}$, $B=\left(\frac{z}{x}\right)^{\frac{1}{c-a}}$, $C=\left(\frac{x}{y}\right)^{\frac{1}{a-b}}$

បង្ហាញថា: $A=B=C$

លំហាត់ទី៨៦

គេមាន: $17!=\overline{3556xy428096000}$ ។ គណនាតម្លៃនៃ $x+y$ ។

លំហាត់ទី៨៧

α និង β ជាឫសពីរផ្សេងគ្នានៃសមីការ $a\cos\theta+b\sin\theta=c$ ។

បង្ហាញថា: $\cos(\alpha+\beta)=\dfrac{a^2-b^2}{a^2+b^2}$ ។

លំហាត់ទី៨៨

គេឲ្យ $\dfrac{\alpha}{\beta}$, $\dfrac{\beta}{\alpha}$ ជាឫសនៃសមីការ $(x+1)^n+x^n+1=0$ ដែល α , β ជាឫសនៃសមីការ $x^2+px+q=0$ ។ បើ α , β ក៏ជាឫសនៃសមីការ $x^{2n}+p^nx^n+q^n=0$ នោះបង្ហាញថា: n ជាចំនួនគត់គូ ដែល $p\neq 0$ ។

លំហាត់ទី៨៩

បើផលគុណឫសពីរនៃសមីការ $x^4-18x^3+kx^2+174x-2015=0$ ក្នុងចំណោមឫសបួនស្មើ -31 ។ គណនាតម្លៃ k ។

លំហាត់ទី៩០

រកចំនួនគត់ a និង b ដើម្បីឲ្យ $ax^{17}+bx^{16}+1$ ចែកដាច់នឹង x^2-x-1

លំហាត់ទី៩១

គេមាន x_1 និង y_1 ជាចំនួនពិត ។ z_1 និង z_2 ជាចំនួនកុំផ្លិច ដែលមាន $|z_1|=|z_2|=4$ ។

បង្ហាញថា: $|x_1z_1-y_1z_2|^2+|y_1z_1+x_1z_2|^2=32\left(x_1^2+y_1^2\right)$

លំហាត់ទី៩២

បើ z_1,z_2,z_3 ជាចំនួនកុំផ្លិចដែល $|z_1|=|z_2|=|z_3|=1$

និង $\dfrac{z_1^2}{z_2z_3}+\dfrac{z_2^2}{z_1z_3}+\dfrac{z_3^2}{z_1z_2}=-1$ ។ គណនា $|z_1+z_2+z_3|$ ។

លំហាត់ទី៩៣

ក្នុងត្រីកោណ ABC មួយមាន $\angle A=2\angle B$ ។ a,b,c ជាជ្រុងឈមនៃមុំ A,B,C រៀងគ្នា ។ បង្ហាញថា $a^2=b(b+c)$ ។

លំហាត់ទី៩៤

គេឲ្យ $\sin x+\sin y=a$ និង $\cos x+\cos y=b$ ។

ស្រាយបញ្ជាក់ថា: $\tan\frac{x}{2}$ និង $\tan\frac{y}{2}$ ជាឫសនៃសមីការ

$\left(a^2+b^2+2b\right)t^2-4at+\left(a^2+b^2-2b\right)=0$ ។

លំហាត់ទី៩៥



ឧបមាថា $A_1A_2A_3...A_n$ ពហុកោណនិយ័ត

មាន n ជ្រុងដែល $\frac{1}{A_1A_2}=\frac{1}{A_1A_3}+\frac{1}{A_1A_4}$ ។

រកចំនួនជ្រុងនៃពហុកោណនោះ ។

លំហាត់ទី៩៦

បង្ហាញថាគ្មានចំនួនគត់ n ណាដែលធ្វើឲ្យកន្សោម

$n^6+3n^5-5n^4-15n^3+4n^2+12n+3$ ជាការេប្រាកដបានទេ ។

លំហាត់ទី៩៧

f ជាអនុគមន៍ពហុធាដែលផ្ទៀងផ្ទាត់លក្ខខណ្ឌ

$2+f(x).f(y)=f(x)+f(y)+f(xy)$; $\forall x,y\in\mathbb{R}$ និង $f(2)=5$ ។

គណនា $f\left(f(1)\right)$ ។

លំហាត់ទី៩៨

f ជាអនុគមន៍ពហុធាផ្ទៀងផ្ទាត់លក្ខខណ្ឌ

$f\left(\tan x\right)+f\left(\cot x\right)=f\left(\tan x\right).f\left(\cot x\right)$, $\forall x\in\left(-\frac{\pi}{2},\frac{\pi}{2}\right)-\{0\}$ និង

$f(2)=9$ ។ គណនាតម្លៃនៃ $\frac{f'(2)}{6}$ ។

លំហាត់ទី៩៩

ឧបមាថា $a,b,c\in\mathbb{R}$ និង $b\neq0$ ។ បើ α,β ជាឫសនៃសមីការ

$x^2+ax+b=0$ និង γ,δ ជាឫសនៃសមីការ $x^2+ax+c=0$ ។

ចូរសរសេរសមីការដែលមានឫស $\dfrac{(\alpha-\gamma)(\alpha-\delta)}{(\beta-\gamma)(\beta-\delta)}$ និង 2 ។

លំហាត់ទី១០០

A,B,C,D ជាបួនចំណុចនៅលើរង្វង់មួយដែលមានផ្ចិត O កាំ R ។ អង្កត់ AC កែងនឹងអង្កត់ BD ត្រង់ E ។

បង្ហាញថា $EA^2+EB^2+EC^2+ED^2=4R^2$ ។

លំហាត់ទី១០១

រកគ្រប់អនុគមន៍ f ដែលផ្ទៀងផ្ទាត់លក្ខខណ្ឌ

$\left[f(x)\right]^2.f\left(\dfrac{1-x}{1+x}\right)=x^3$, $x\neq -1$ និង $f(x)\neq 0$ ។

លំហាត់ទី១០២

សន្មតថា $S=\dfrac{1}{n^4}\displaystyle\prod_{r=1}^{2n}\left(n^2+r^2\right)$ ។

បង្ហាញថា: $\displaystyle\lim_{n\to\infty}\log S=\int_0^2\log\left(x^2-4x+5\right)dx$ ។

លំហាត់ទី១០៣

គេឲ្យ $p=\left(1+\cos\dfrac{\pi}{10}\right)\left(1+\cos\dfrac{3\pi}{10}\right)\left(1+\cos\dfrac{7\pi}{10}\right)\left(1+\cos\dfrac{9\pi}{10}\right)$

$q=\left(1+\cos\dfrac{\pi}{8}\right)\left(1+\cos\dfrac{3\pi}{8}\right)\left(1+\cos\dfrac{7\pi}{8}\right)\left(1+\cos\dfrac{9\pi}{8}\right)$

រកទំនាក់ទំនងរវាង p និង q ។

លំហាត់ទី១០៤

បង្ហាញថា $\tan\dfrac{\pi}{16}=\sqrt{4+2\sqrt{2}}-\left(\sqrt{2}+1\right)$

លំហាត់ទី១០៥

បើ a,b,c ជាបីចំនួនពិតវិជ្ជមាន និង $a+b+c=6$ ។

រកតម្លៃតូចបំផុតនៃកន្សោម $\left(a+\frac{1}{b}\right)^2+\left(b+\frac{1}{c}\right)^2+\left(c+\frac{1}{a}\right)^2$

លំហាត់ទី១០៦

បើ a,b,c ជាបីចំនួនពិតវិជ្ជមាន ។

រកតម្លៃអប្បបរមានៃកន្សោម $\frac{a^2+1}{b+c}+\frac{b^2+1}{c+a}+\frac{c^2+1}{a+b}$

លំហាត់ទី១០៧ USAJMO 2012

គេមាន a,b,c ជាចំនួនពិតវិជ្ជមាន ។

បង្ហាញថា: $\frac{a^3+3b^3}{5a+b}+\frac{b^3+3c^3}{5b+c}+\frac{c^3+3a^3}{5c+a}\geq\frac{2}{3}\left(a^2+b^2+c^2\right)$

លំហាត់ទី១០៨

បើ $a_1,a_2,a_3,...,a_{4001}$ ជាតួនៃស្វ៊ីតនព្វន្ត ហើយមាន

$\frac{1}{a_1a_2}+\frac{1}{a_2a_3}+...+\frac{1}{a_{4000}a_{4001}}=10$ និង $a_1+a_{4001}=50$ ។

គណនា $|a_1-a_{4001}|$ ។

លំហាត់ទី១០៩

ត្រីកោណ ABC មួយមានរង្វាស់ជ្រុងទាំងបី a,b,c បង្កើតបានជាស្វ៊ីតនព្វន្តដែលមាន a ជាតួមធ្យម ។

បង្ហាញថា $\tan\frac{B}{2}\tan\frac{C}{2}=\frac{1}{3}$ ។

លំហាត់ទី១១០

គេឲ្យត្រីកោណ ABC មួយ និង D,E,F ជាចំណុចនៅលើជ្រុង BC,CA,AB រៀងគ្នា ។ បើ $AFDE$ ជាចតុកោណចារឹកក្នុងរង្វង់

បង្ហាញថា $\frac{4S_{DEF}}{S_{ABC}}\leq\left(\frac{EF}{AD}\right)^2$ ។

លំហាត់ទី១១១

រង្វង់ពីរកាត់គ្នាត្រង់ចំណុច A និង B ។ P ជាចំណុចមួយនៅលើធ្នូ AB នៃរង្វង់មួយ ។ បន្ទាត់ PA និង PB កាត់រង្វង់មួយទៀតត្រង់ចំណុច R និង S (ដូចរូប) ។ បើ P' ជាចំណុចមួយនៅលើធ្នូ AB នៃរង្វង់ទី១ ហើយ $P'A$ និង $P'B$ កាត់រង្វង់មួយទៀតត្រង់ R' និង S' ។ បង្ហាញថាប្រវែងអង្កត់ធ្នូ $RS = R'S'$ ។

លំហាត់ទី១១២

កំណត់ក្រឡាផ្ទៃ S នៃត្រីកោណ ABC មួយដែលមានជ្រុង a , b , c និង ជា p កន្លះបរិមាត្រ បើគេដឹងថា

$$(p-b)(p-c)=\frac{a}{h}\,,\,(p-a)(p-c)=\frac{b}{k}\,,\,(p-a)(p-b)=\frac{c}{l}$$

ដែល h , k , l ជាចំនួនថេរ ។

លំហាត់ទី១១៣

បើ $a_1, a_2, a_3, ..., a_{2015}$ ជាតួនៃស្វ៊ីតនព្វន្តដែល $\sum_{r=1}^{2014}\frac{1}{a_r a_{r+1}}=\frac{2014}{2013}$

និង $a_{101}+a_{305}+a_{509}+a_{1507}+a_{1711}+a_{1915}=6042$ ។

សរសេរសមីការដែលមានឫស a_1 និង a_{2015} ។

លំហាត់ទី១១៤

ស្វ៊ីតនៃចំនួនពិត (a_n) មួយមាន $a_0 = a_1 = 1$ និង

$\sqrt{a_n.a_{n-2}}-\sqrt{a_{n-1}.a_{n-2}}=2a_{n-1}$ ចំពោះ $n\geq 2$ ។

កំណត់តួទី n នៃស្វ៊ីត (a_n) ។

លំហាត់ទី១១៥

គណនាតម្លៃនៃកន្សោមខាងក្រោម:

$$A=\frac{1}{4029}+\frac{2\times 2014}{2014^2+2015^2}+\frac{4\times 2014^3}{2014^4+2015^4}-\frac{8\times 2014^7}{2014^8-2015^8}$$

លំហាត់ទី១១៦

គេឲ្យប្រព័ន្ធសមីការខាងក្រោម:

$$\begin{cases} x_1+x_2=x_2+x_3=x_3+x_4=...=x_{2014}+x_{2015}=x_{2015}+x_{2016}=1 \\ x_1+x_2+x_3+...+x_{2015}+x_{2016}=x_{2016} \end{cases}$$

គណនាតម្លៃ x_1 ។

លំហាត់ទី១១៧

គេឲ្យ n ជាចំនួនគត់វិជ្ជមាន ហើយ $n<1000$ ។ បើ $n^{2014}-1$ ចែកដាច់នឹង $(n-1)^2$ ។ គណនាតម្លៃធំបំផុតនៃ n ។

លំហាត់ទី១១៨

បើ $x^3+x^2+x+1=0$ ។ គណនាតម្លៃផលបូកខាងក្រោម:

$$S=x^{-2014}+x^{-2013}+x^{-2012}+...+x^{-1}+1+x+x^2+...+x^{2013}+x^{2014}$$

លំហាត់ទី១១៩

ត្រីកោណ ABC មួយមាន $AB=32$, $AC=15$ និង $BC=x$ ដែល x ជាចំនួនគត់វិជ្ជមាន ។ D និង E ជាចំណុចនៅលើជ្រុង AB និង AC រៀងគ្នាដែល $AD=DE=EC=y$ និង y ជាចំនួនគត់វិជ្ជមាន ។ គណនាតម្លៃ x ។

លំហាត់ទី១២០

$ABCD$ ជាចតុកោណចារឹកក្នុងរង្វង់ដែលមាន $AD=5$, $DC=14$, $BC=10$ និង $AB=11$ ។

គណនាក្រឡាផ្ទៃចតុកោណ $ABCD$ ។

លំហាត់ទី១២១

គេឲ្យ a,b,c ជាបីចំនួនថេរផ្សេងគ្នា និងមានសមីការ

$$\frac{a^2}{(a-b)(a-c)(a+x)}+\frac{b^2}{(b-c)(b-a)(b+x)}+\frac{c^2}{(c-a)(c-b)(c+x)}$$

$$=\frac{p+qx+rx^2}{(a+x)(b+x)(c+x)}$$ ដែល p,q,r ជាចំនួនថេរ

និង $S=7p+8q+9r$ ។ គណនាតម្លៃនៃ S ។

លំហាត់ទី១២២

គេមានទំនាក់ទំនងខាងក្រោម:

$$b\left(\frac{1}{1\times 3}+\frac{1}{3\times 5}+...+\frac{1}{1999\times 2001}\right)=2\left(\frac{1^2}{1\times 3}+\frac{2^2}{3\times 5}+...+\frac{1000^2}{1999\times 2001}\right)$$

គណនាតម្លៃនៃ b ។

លំហាត់ទី១២៣

គេឲ្យ a,b ជាចំនួនពិតវិជ្ជមាន និងសមីការ $x^2+ax+b=0$

$x^2+2bx+a=0$ មានឫសជាចំនួនពិត ។

គណនាតម្លៃតូចបំផុតនៃ $a+b$ ។

លំហាត់ទី១២៤

តាង k ជាចំនួនគត់វិជ្ជមាន និង $f(k)$ ជាអនុគមន៍មួយ

បើ $\frac{k-1}{k}=0.\overline{k_1k_2k_3...}$ នោះ $f(k)=\overline{k_1k_2k_3}$ ។

ឧទាហរណ៍ $f(3)=666$ ព្រោះ $\frac{3-1}{3}=0.666...$

គណនា $D=f(f(f(f(f(112)))))$ ។

លំហាត់ទី១២៥

ត្រីកោណ ABC មួយមានប្រវែងជ្រុងទាំងបីបង្កើតបានជាស្វ៊ីតនព្វន្ត និង ជាឫសនៃសមីការ $x^3-12x^2+47x-60=0$ ។

គណនាក្រឡាផ្ទៃត្រីកោណ ABC នោះ ។

លំហាត់ទី១២៦

បើ x ជាចំនួនពិត និង d ជាតម្លៃធំបំផុតនៃប្រភាគ $y=\frac{3x^2+3x+4}{x^2+x+1}$

គណនាតម្លៃ d ។

លំហាត់ទី១២៧

បើ a និង b ជាចំនួនពិត ដែល $a^2+b^2=a+b$ ។
គណនាតម្លៃធំបំផុតនៃ $a+b$ ។

លំហាត់ទី១២៨

$ABCD$ ជាចតុកោណកែងមួយដែលមាន $AB=\sqrt{\frac{8+\sqrt{64-\pi^2}}{\pi}}$ និង $BC=\sqrt{\frac{8-\sqrt{64-\pi^2}}{\pi}}$ ។ BE និង BF ជាប្រវែងធ្នូ នៃរង្វង់ដែលមានផ្ចិត C និង A រៀងគ្នា ។
គណនាផលបូកក្រឡាផ្ទៃផ្នែកឆូត ។



លំហាត់ទី១២៩

គេឲ្យពហុកោណនិយ័តមួយដែលមានជ្រុង 12 ។ x,y,z,w ជាកំពូល 4 ដែលជាប់តគ្នា ។ បើ $xy=2$ និងក្រឡាផ្ទៃចតុកោណ $xyzw$ ស្មើ $a+\sqrt{b}$ ។ គណនាតម្លៃ $B=2^a.3^b$ ។

លំហាត់ទី១៣០

T ជាចំណុចមួយនៅក្នុងត្រីកោណសម័ង្ស PQR ដែល $TP=3$ $TQ=3\sqrt{3}$ និង $TR=6$ (ដូចរូប) ។ គណនា $\angle PTR$ ។



លំហាត់ទី១៣១

P , B និង C ជាចំណុចនៅលើរង្វង់ដែលមានផ្ចិត O និងអង្កត់ BC (ដូចរូប) ។ បើ A,B,C,D រត់ត្រង់គ្នាហើយ $AB=BC=CD$ $\alpha=\angle APB$ និង $\beta=\angle CPD$ ។ គណនាតម្លៃនៃ $(\tan\alpha)(\tan\beta)$



លំហាត់ទី១៣២

គេឲ្យ a,b,x និង y ជាចំនួនគត់មិនសូន្យ ដែល $ax+by=4$
$ax^2+by^2=22$, $ax^3+by^3=46$ និង $ax^4+by^4=178$ ។
គណនាតម្លៃនៃ ax^5+by^5 ។ (HKMO 2015)

ផ្នែកទី៣ ដំណោះស្រាយ

លំហាត់ទី១

គេឲ្យស្វ៊ីតនព្វន្ត $\alpha_1, \alpha_2, ..., \alpha_{45}$ ដែលមានតួទី 1 គឺ $\alpha_1 = 1^o$ និង ផលសងរួម $d = 4^o$ ។ ស្រាយបញ្ជាក់ថា $\sum_{i=1}^{45} \tan \alpha_i = 45$ ។

ដំណោះស្រាយ

ស្រាយបញ្ជាក់ថា $\sum_{i=1}^{45} \tan \alpha_i = 45$

តួទី 45 នៃស្វ៊ីតនព្វន្ត (α_n) គឺ: $\alpha_{45} = \alpha_1 + 44d = 1^0 + 44 \times 4^0 = 177^0$

ចំពោះ $\forall \alpha$ គេបាន:

$$\tan \alpha + \tan(\alpha + 60^0) + \tan(\alpha + 120^0) = 3\tan 3\alpha \quad (1)$$

យក $\alpha = 1^0 + 4^0 k$ ដែល $k = 0, 1, 2, ..., 14$ នោះតាម (1) គេបាន:

$$\tan 1^0 + \tan 61^0 + \tan 121^0 = 3\tan 3^0$$

$$\tan 5^0 + \tan 65^0 + \tan 125^0 = 3\tan 15^0$$

$$\tan 9^0 + \tan 69^0 + \tan 129^0 = 3\tan 27^0$$

....

$$\tan 53^0 + \tan 113^0 + \tan 173^0 = 3\tan 159^0$$

$$\tan 57^0 + \tan 117^0 + \tan 177^0 = 3\tan 171^0$$

បូកអង្គនឹងអង្គគេបាន:

$$\sum_{k=1}^{45}\tan\alpha_k = 3(\tan 3^0+\tan 63^0+\tan 123^0)+3(\tan 15^0+\tan 75^0+\tan 135^0)$$
$$+3(\tan 27^0+\tan 87^0+\tan 147^0)+3(\tan 39^0+\tan 99^0+\tan 159^0)$$
$$+3(\tan 51^0+\tan 111^0+\tan 171^0) \quad (2)$$

តាម (1) និង (2) គេបាន:

$$\sum_{k=1}^{45}\tan\alpha_k = 9(\tan 9^0+\tan 45^0+\tan 81^0+\tan 117^0+\tan 153^0)$$
$$=9(\tan 9^0+\tan 81^0-\tan 63^0-\tan 27^0)+9$$

យើងមាន: $\tan 9^0+\tan 81^0-\tan 63^0-\tan 27^0$

$$=\frac{\sin(81^0+9^0)}{\cos 9^0\cos 81^0}-\frac{\sin(63^0+27^0)}{\cos 63^0\cos 27^0}=\frac{1}{\sin 9^0\cos 9^0}-\frac{1}{\sin 27^0\cos 27^0}$$

$=\dfrac{2(\sin 54^0-\sin 18^0)}{\sin 18^0\sin 54^0}=\dfrac{4\cos 36^0\sin 18^0}{\sin 18^0\sin 54^0}=4$ (3) តាម (4) និង (3) គេបាន: $\sum_{i=1}^{45}\tan\alpha_i=45$

លំហាត់ទី២

គេឲ្យ $k\in\mathbb{N}$ និង $a_1,a_2,\ldots,a_n$ ជាចំនួនពិតវិជ្ជមានដែលផ្ទៀងផ្ទាត់ថា: $a_1+a_2+\cdots+a_n=1$ ។ ស្រាយថា: $a_1^{-k}+a_2^{-k}+\cdots+a_n^{-k}\ge n^{k+1}$ ។

ដំណោះស្រាយ

ស្រាយថា: $a_1^{-k}+a_2^{-k}+\cdots+a_n^{-k}\ge n^{k+1}$

តាមវិសមភាព $AM\ge GM$ គេបាន:

$$\sqrt[n]{a_1a_2\ldots a_n}\le\frac{a_1+a_2+\cdots+a_n}{n}=\frac{1}{n}$$

$$\Leftrightarrow n\le\sqrt[n]{\frac{1}{a_1}\cdot\frac{1}{a_2}\cdots\frac{1}{a_n}}$$

$\Rightarrow n^k \le \sqrt[n]{a_1^{-k}.a_2^{-k}...a_n^{-k}} \le \dfrac{a_1^{-k}+a_2^{-k}+\cdots+a_n^{-k}}{n}$

$a_1^{-k}+a_2^{-k}+\cdots+a_n^{-k} \ge n^{k+1}$ ពិត

ដូចនេះ វិសមភាពត្រូវបានស្រាយបញ្ជាក់ ។

លំហាត់ទី៣

គេឲ្យស្វ៊ីតនៃចំនួនពិតកំណត់ដោយ $A=\{a_1,a_2,a_3,\ldots\}$ ។ កំណត់យក ΔA ជាស្វ៊ីតដែល $\Delta A=\{a_2-a_1,a_3-a_2,a_4-a_3,\ldots\}$ សន្មតថាគ្រប់តួនៃស្វ៊ីត $\Delta(\Delta A)$ គឺ 1 ដែល $a_{19}=a_{92}=0$ ។ រក a_1

ដំណោះស្រាយ

រក a_1

សន្មតថាតួដំបូងនៃស្វ៊ីត ΔA គឺ d នោះ

$\Delta A=\{d,a_1+1,a_1+2,\ldots\}$

តួទី n នៃស្វ៊ីត ΔA កំណត់ដោយ: $d+(n-1)$

$\Rightarrow A=\{a_1,a_1+d,a_1+2d+1,a_1+3d+3,\ldots\}$

តួទី n នៃស្វ៊ីត A កំណត់ដោយ: $a_n=a_1+(n-1)d+\dfrac{1}{2}(n-1)(n-2)$

ដោយ $a_{19}=a_{92}=0$ គេបាន:

$$\begin{cases} a_{19}=a_1+18d+\dfrac{1}{2}\cdot 18\cdot 17=0 \\ a_{92}=a_1+91d+\dfrac{1}{2}\cdot 91\cdot 90=0 \end{cases}$$

$\Rightarrow a_1=819$

ដូចនេះ $a_1=819$ ។

លំហាត់ទី៤

គេឲ្យស្វ៊ីត *Fibonacci* មួយកំណត់ដោយ: $f_1 = f_2 = 1$ និង $f_{n+2} = f_{n+1} + f_n \, (n \in \mathbb{N})$ ។ ស្រាយថា: $f_{2n} = \dfrac{f_{2n+2}^3 + f_{2n-2}^3}{9} - 2f_{2n}^3$ ចំពោះគ្រប់ $n \geq 2$ ។

ដំណោះស្រាយ

ស្រាយថា: $f_{2n} = \dfrac{f_{2n+2}^3 + f_{2n-2}^3}{9} - 2f_{2n}^3$ ចំពោះគ្រប់ $n \geq 2$

យើងមាន:

$$f_{2n+2} - 3f_{2n} = f_{2n+1} - 2f_{2n} = f_{2n-1} - f_{2n} = -f_{2n-2}$$

$$\Leftrightarrow 3f_{2n} - f_{2n+2} - f_{2n-2} = 0 \; (1)$$

ចំពោះ $n \geq 2$

តាង $a = 3f_{2n}, b = -f_{2n+2}$ និង $c = -f_{2n-2}$ តាមសមភាព

$$a^3 + b^3 + c^3 - 3abc$$

$$= (a+b+c)(a^2 + b^2 + c^2 - ab - bc - ac)$$

គេបាន:

$$27f_{2n}^3 - f_{2n+2}^3 - f_{2n-2}^3 - 9f_{2n+2}f_{2n}f_{2n-2} = 0$$

$$f_{2n+2}^3 + f_{2n-2}^3 - 18f_{2n}^3 = -9f_{2n+2}f_{2n}f_{2n-2} + 9f_{2n}^3 \; (2)$$

យើងមាន:

$$f_{2n+2}f_{2n-2} - f_{2n}^2 = (3f_{2n} - f_{2n-2})f_{2n-2} - f_{2n}^2$$

$$= f_{2n}(3f_{2n-2} - f_{2n}) - f_{2n-2}^2 = f_{2n}f_{2n-4} - f_{2n-2}^2$$

$$= \cdots = f_6 f_2 - f_4^2 = -1$$

$$\Rightarrow -9f_{2n+2}f_{2n}f_{2n-2} + 9f_{2n}^3$$

$= -9 f_{2n}(f_{2n+2} f_{2n-2} - f_{2n}^2)$

$= 9 f_{2n}$

តាម (2) គេបាន: $f_{2n+2}^3 + f_{2n-2}^3 - 18 f_{2n}^3 = 9 f_{2n}$

$\Leftrightarrow f_{2n} = \dfrac{f_{2n+2}^3 + f_{2n-2}^3}{9} - 2 f_{2n}^3$ ពិត

ដូចនេះ សមភាពត្រូវបានស្រាយបញ្ជាក់ ។

លំហាត់ទី៥

ដោះស្រាយសមីការ: $2^x + 3^x - 4^x + 6^x - 9^x = 1$

ដំណោះស្រាយ

ដោះស្រាយសមីការ: $2^x + 3^x - 4^x + 6^x - 9^x = 1$

តាង $a = 2^x, b = 3^x$ គេបាន:

$a + b - a^2 + ab - b^2 = 1$

$2a^2 + 2b^2 - 2ab - 2a - 2b + 2 = 0$

$(a-b)^2 + (a-1)^2 + (b-1)^2 = 0$

$$\Rightarrow \begin{cases} a - b = 0 \\ a - 1 = 0 \\ b - 1 = 0 \end{cases} \Rightarrow \begin{cases} 2^x = 3^x \\ 2^x = 1 \\ 3^x = 1 \end{cases}$$

$\Rightarrow x = 0$

ដូចនេះ $x = 0$ ជាឬសនៃសមីការ ។

លំហាត់ទី៦

គណនាតម្លៃនៃកន្សោម: $A = \sum_{k=0}^{n} \binom{n}{k} k^2$ ។

ដំណោះស្រាយ

គណនាតម្លៃនៃកន្សោម: $A=\sum_{k=0}^{n}\binom{n}{k}k^2$

យើងមាន: $\sum_{k=0}^{n}\binom{n}{k}k^2$

$$=\sum_{k=0}^{n}\binom{n}{k}k(k-1+1)$$

$$=\sum_{k=0}^{n}\binom{n}{k}k(k-1)+\sum_{k=0}^{n}\binom{n}{k}k$$

$$=n\sum_{k=1}^{n}\binom{n-1}{k-1}(k-1)+n\sum_{k=1}^{n}\binom{n-1}{k-1}$$

$$=n(n-1)\sum_{k=2}^{n}\binom{n-2}{k-2}+n\sum_{k=0}^{n}\binom{n-1}{k}$$

$$=n(n-1)\sum_{k=0}^{n}\binom{n-2}{k}+n.2^{n-1}$$

$$=n(n-1).2^{n-2}+n.2^{n-1}$$

$$=n(n+1)2^{n-2}$$

ដូចនេះ $A=\sum_{k=0}^{n}\binom{n}{k}k^2=n(n+1)2^{n-2}$ ។

លំហាត់ទី៧

គេឲ្យ $\frac{a}{bc-a^2}+\frac{b}{ac-b^2}+\frac{c}{ab-c^2}=0$ ។ ស្រាយថា:

$$\frac{a}{(bc-a^2)^2}+\frac{b}{(ac-b^2)^2}+\frac{c}{(ab-c^2)^2}=0$$ ។

ដំណោះស្រាយ

ស្រាយថា: $\frac{a}{(bc-a^2)^2}+\frac{b}{(ac-b^2)^2}+\frac{c}{(ab-c^2)^2}=0$

តាង $A=\frac{1}{bc-a^2}+\frac{1}{ac-b^2}+\frac{1}{ab-c^2}$

$$B=\frac{a}{bc-a^2}+\frac{b}{ac-b^2}+\frac{c}{ab-c^2}$$

$$C=\frac{a}{(bc-a^2)^2}+\frac{b}{(ac-b^2)^2}+\frac{c}{(ab-c^2)^2}$$

$$\Rightarrow AB=\frac{a}{(bc-a^2)^2}+\frac{b}{(bc-a^2)(ac-b^2)}+\frac{c}{(bc-a^2)(ab-c^2)}$$

$$+\frac{a}{(bc-a^2)(ac-b^2)}+\frac{b}{(ac-b^2)^2}+\frac{c}{(ac-b^2)(ab-c^2)}$$

$$+\frac{a}{(bc-a^2)(ab-c^2)}+\frac{b}{(ab-c^2)(ac-b^2)}+\frac{c}{(ab-c^2)^2}$$

$$\Leftrightarrow AB=C+\frac{b(ab-c^2)+b(bc-a^2)}{(ab-c^2)(bc-a^2)(ac-b^2)}+\frac{a(ab-c^2)+a(ac-b^2)}{(ab-c^2)(bc-a^2)(ac-b^2)}$$

$$+\frac{c(ac-b^2)+c(bc-a^2)}{(ab-c^2)(bc-a^2)(ac-b^2)}$$

$\Rightarrow C=0$ ពិត

ដូចនេះ សមភាពត្រូវបានស្រាយបញ្ជាក់ ។

លំហាត់ទី៨

គេឲ្យ a,b ជាការេនៃពីរចំនួនគត់សេសវិជ្ជមានតគ្នា។

ស្រាយថា: $ab-a-b+1\vdots 192$ ។

ដំណោះស្រាយ

ស្រាយថា: $ab-a-b+1\vdots 192$

ដោយ a,b ជាចំនួនគត់សេសវិជ្ជមានតគ្នាគេបាន:

$a=(2n-1)^2, b=(2n+1)^2 \ , n\in\mathbb{N}$

$a=4n^2-4n+1 \ , \ b=4n^2+4n+1$

$a-1=4n(n-1) \ , \ b-1=4n(n+1)$

$\Rightarrow (a-1)(b-1)=16n^2(n-1)(n+1)$

$\Leftrightarrow ab-a-b+1=16n^2(n-1)(n+1)$

ដោយ $n(n-1)\vdots 2, n(n+1)\vdots 2, n(n-1)(n+1) \ \vdots 6$

$\Rightarrow ab-a-b+1\vdots 192$ ពិត

ដូចនេះ $ab-a-b+1\vdots 192$ ។

លំហាត់ទី៩

រកចំនួន $\overline{xyz}$ ដែលផ្ទៀងផ្ទាត់ថា: $\overline{xyz}+\overline{xzy}=\overline{zzz}$ ។

ដំណោះស្រាយ

រកចំនួន $\overline{xyz}$

លក្ខខណ្ឌ: $0<x,z\le 9; 0\le y\le 9$

យើងមាន: $\overline{xyz}+\overline{xzy}=\overline{zzz}$

$100x+10y+z+100x+10z+y=111z$

$200x+11y=100z \ (*)$

$11y\equiv 0 \pmod{100}$

$\Rightarrow y=0$

តាម $(*)$ គេបាន: $2x=z$

$\Rightarrow \overline{xyz}=102, 204, 306, 408$

ដូចនេះ ចំនួនដែលត្រូវរកគឺ $102, 204, 306, 408$ ។

លំហាត់ទី១០

ស្រាយថា: $7^{9^{9^{9^{9}}}} - 7^{9^{9}} \vdots 100$ ។

ដំណោះស្រាយ

ស្រាយថា: $7^{9^{9^{9^{9}}}} - 7^{9^{9}} \vdots 100$

យើងមាន: $9^{9} = 4l + 1, l \in \mathbb{N}^{*}$

$\Rightarrow 9^{9^{9^{9}}} = 4k + 1, k \in \mathbb{N}^{*}$

$\Rightarrow 7^{9^{9^{9^{9}}}} = 7^{4k+1} = 7.2401^{k} \equiv 7(\text{mod}100)$

$\Rightarrow 7^{9^{9}} = 7^{4l+1} = 7.2401^{l} \equiv 7(\text{mod}100)$

$\Rightarrow 7^{9^{9^{9^{9}}}} - 7^{9^{9}} \equiv 0(\text{mod}100)$

$\Rightarrow 7^{9^{9^{9^{9}}}} - 7^{9^{9}} \vdots 100$ ពិត

ដូចនេះ $7^{9^{9^{9^{9}}}} - 7^{9^{9}} \vdots 100$ ។

លំហាត់ទី១១

គេឲ្យស្វ៊ីត (u_n) កំណត់ដោយ: $u_0 = u_1 = u_2 = 1$ និង

$\det\begin{pmatrix} u_{n+3} & u_{n+2} \\ u_{n+1} & u_n \end{pmatrix} = n!, n \geq 0$ ។

ស្រាយថាគ្រប់តួនៃស្វ៊ីត (u_n) ជាចំនួន គត់ចំពោះគ្រប់ n ។

ដំណោះស្រាយ

ស្រាយថាគ្រប់តួនៃស្វ៊ីត (u_n) ជាចំនួនគត់ចំពោះគ្រប់ n

យើងមាន: $\det\begin{pmatrix} u_{n+3} & u_{n+2} \\ u_{n+1} & u_n \end{pmatrix} = n!$

$u_{n+3}.u_n - u_{n+1}.u_{n+2} = n!$

$u_{n+3}.u_n = u_{n+1}.u_{n+2} + n!$

$u_{n+3} = \dfrac{u_{n+1}.u_{n+2}}{u_n} + \dfrac{n!}{u_n}$

$u_3 = \dfrac{1.1}{1} + \dfrac{1}{1} = 2$

$u_4 = \dfrac{2.1}{1} + \dfrac{1}{1} = 3$

$u_5 = \dfrac{3.2}{1} + \dfrac{2}{1} = 4.2$

$u_6 = \dfrac{4.2.3}{2} + \dfrac{3.2}{2} = 4.3 + 3 = 5.3$

$u_7 = \dfrac{5.3.4.2}{3} + \dfrac{4.3.2}{3} = 5.4.2 + 4.2 = 6.4.2$

$u_8 = \dfrac{6.4.2.5.3}{4.2} + \dfrac{5.4.3.2}{4.2} = 6.5.3 + 5.3 = 7.5.3$

យើងសង្កេតឃើញថា: $u_n = (n-1)(n-3)(n-5)\dots$ ជាចំនួនគត់ សន្មត ថារូបមន្តទូទៅនេះពិតដល់តួទី u_n, u_{n+1} និង u_{n+2}

យើងត្រូវស្រាយថាវាពិតដល់តួទី u_{n+3}

យើងមាន: $u_{n+3} = \dfrac{u_{n+1}.u_{n+2}}{u_n} + \dfrac{n!}{u_n}$

$$= \frac{(n+1)(n-1)(n-3)\dots n(n-2)(n-4)\dots + n!}{(n-1)(n-3)(n-5)\dots}$$

$$= \frac{(n+1)n! + n!}{(n-1)(n-3)(n-5)\dots}$$

$$= \frac{(n+2)n!}{(n-1)(n-3)(n-5)\dots}$$

$$= (n+2)n(n-2)(n-4)\dots$$

នេះបញ្ជាក់ថាតួទី u_{n+3} ជាចំនួនគត់

ដូចនេះ គ្រប់តួនៃស្វ៊ីត (u_n) ជាចំនួនគត់ចំពោះគ្រប់ n ។

លំហាត់ទី១២

រកតួទូទៅនៃស្វ៊ីត (T_n) ដែលកំណត់ដោយ $T_1 = 1, T_n = T_{\sqrt{n}} + c\log_2 n$ ហើយ c ជាចំនួនថេរ ។

ដំណោះស្រាយ

រកតួទូទៅនៃស្វ៊ីត (T_n)

សមីការអូម៉ូសែន: $T_n - T_{\sqrt{n}} = 0$

សមីការសម្គាល់ស្វ៊ីត: $x - \sqrt{x} = 0$

$x^2 - x = 0$

$x = 0, x = 1$

$\Rightarrow T_{n_1} = A.0^n + B.1^n = B$

ដោយ $x_1 = 0$, $x_2 = 1 \neq c\log_2 n$

$T_{n_2} = Zc\log_2 n$

$\Leftrightarrow Zc\log_2 n - \dfrac{1}{2}Zc\log_2 n = c\log_2 n$

$\Leftrightarrow Z - \dfrac{1}{2}Z = 1$

$\Leftrightarrow Z = 2$

$T_{n_2} = 2c\log_2 n$

$\Rightarrow T_n = T_{n_1} + T_{n_2} = B + 2c\log_2 n$

បើ $n = 1 : T_1 = B + 2c\log_2 1 = 1 \Rightarrow B = 1$

$\Rightarrow T_n = 1 + 2c\log_2 n$

ដូចនេះ $T_n = 1 + 2c\log_2 n$ ។

លំហាត់ទី១៣

គេឲ្យ $x, y, z \ge 0$ ដែល $x + y + z = 6$ រកតម្លៃតូចបំផុតនៃកន្សោម:

$$S = \frac{2015}{7 + 3\ln(x+1) - y} + \frac{2015}{7 + 3\ln(y+1) - z} + \frac{2015}{7 + 3\ln(z+1) - z}$$ ។

ដំណោះស្រាយ

រកតម្លៃតូចបំផុតនៃកន្សោម:

$$S = \frac{2015}{7 + 3\ln(x+1) - y} + \frac{2015}{7 + 3\ln(y+1) - z} + \frac{2015}{7 + 3\ln(z+1) - z}$$

ដោយ: $x, y, z \ge 0$ ដែល $x + y + z = 6 \Rightarrow 0 \le x, y, z \le 6$

$$\Rightarrow 7 + 3\ln(x+1) - y > 0, 7 + 3\ln(y+1) - z > 0, 7 + 3\ln(z+1) - z > 0$$

តាមវិសមភាព $Cauchy - Swcharz$ គេបាន:

$$\frac{(\sqrt{2015})^2}{7 + 3\ln(x+1) - y} + \frac{(\sqrt{2015})^2}{7 + 3\ln(y+1) - z} + \frac{(\sqrt{2015})^2}{7 + 3\ln(z+1) - z}$$

$$\ge \frac{(3\sqrt{2015})^2}{21 + 3\ln(x+1) + 3\ln(y+1) + 3\ln(z+1) - x - y - z}$$

$$= \frac{18135}{15 + 3\ln(x+1)(y+1)(z+1)}$$

តាមវិសមភាព $Cauchy$ គេបាន:

$$\sqrt[3]{(x+1)(y+1)(z+1)} \le \frac{x + y + z + 3}{3} = 3$$

$$\Rightarrow \frac{1}{3}\ln(x+1)(y+1)(z+1) \le \ln 3$$

$$\Rightarrow 15+3\ln(x+1)(y+1)(z+1)\le 15+9\ln 3$$

$$\Rightarrow \frac{18135}{15+3\ln(x+1)(y+1)(z+1)}\ge \frac{18135}{15+9\ln 3}=\frac{6045}{5+3\ln 3}$$

ដូចនេះ តម្លៃតូចបំផុតនៃ S គឺ: $\frac{6045}{5+3\ln 3}$ ។

លំហាត់ទី១៤

គេឲ្យត្រីកោណ ABC មួយស្រាយថា:

$$\sin^3 A\sin(B-C)+\sin^3 B\sin(C-A)+\sin^3 C\sin(A-B)=0$$

ដំណោះស្រាយ

ស្រាយថា: $\sin^3 A\sin(B-C)+\sin^3 B\sin(C-A)+\sin^3 C\sin(A-B)=0$

យើងមាន: $A+B+C=\pi$

$\Rightarrow \sin(\pi-A)=\sin(B+C)\Rightarrow \sin A=\sin(B+C)$ គេបាន:

$$\sin^3 A\sin(B-C)=\sin^2 A\sin(B+C)\sin(B-C)$$

$$=-\frac{1}{4}(1-\cos 2A)(\cos 2B-\cos 2C)$$

$$=-\frac{1}{4}(\cos 2B-\cos 2C-\cos 2A\cos 2B+\cos 2A\cos 2C)$$

ស្រាយដូចគ្នាដែរ

$$\sin^3 B\sin(C-A)=-\frac{1}{4}(\cos 2C-\cos 2A-\cos 2B\cos 2C+\cos 2B\cos 2A)$$

$$\sin^3 C\sin(A-B)=-\frac{1}{4}(\cos 2A-\cos 2B-\cos 2C\cos 2A+\cos 2C\cos 2B)$$

គេបាន:

$\sin^3 A\sin(B-C)+\sin^3 B\sin(C-A)+\sin^3 C\sin(A-B)=0$ ពិត

ដូចនេះ សមភាពត្រូវបានស្រាយបញ្ជាក់ ។

លំហាត់ទី១៥

គេឲ្យត្រីកោណ ABC មួយស្រាយថា:

$$\frac{a\sin A+b\sin B+c\sin C}{a\cos A+b\cos B+c\cos C}=\cot A+\cot B+\cot C$$ ។

ដំណោះស្រាយ

ស្រាយថា: $\dfrac{a\sin A+b\sin B+c\sin C}{a\cos A+b\cos B+c\cos C}=\cot A+\cot B+\cot C$

តាមទ្រឹស្តីបទស៊ីនុស: $\dfrac{a}{\sin A}=\dfrac{b}{\sin B}=\dfrac{c}{\sin C}=2R$

$$\Rightarrow\begin{cases}a=2R\sin A\\ b=2R\sin B\\ c=2R\sin C\end{cases}$$

$$\Rightarrow\frac{a\sin A+b\sin B+c\sin C}{a\cos A+b\cos B+c\cos C}=\frac{2R(\sin^2 A+\sin^2 B+\sin^2 C)}{R(2\cos\mathrm{A}\sin\mathrm{A}+\cos\mathrm{B}\sin\mathrm{B}+\cos C\sin\mathrm{C})}$$

$$=\frac{2(\sin^2 A+\sin^2 B+\sin^2 C)}{\sin 2A+\sin 2B+\sin 2C}$$

$$=\frac{2(\sin^2 A+\sin^2 B+\sin^2 C)}{2\sin(A+B)\cos(A-B)+2\sin C\cos C}$$

$$=\frac{\sin^2 A+\sin^2 B+\sin^2 C}{\sin C\left[\cos(\mathrm{A-B})-\cos(\mathrm{A+B})\right]}$$

$$=\frac{\sin^2 A+\sin^2 B+\sin^2 C}{2\sin A\sin B\sin C}$$

$$=\frac{1}{2}\left(\frac{\sin A}{\sin B\sin C}+\frac{\sin B}{\sin A\sin C}+\frac{\sin C}{\sin A\sin B}\right)$$

$$=\frac{1}{2}\left(\frac{\sin(B+C)}{\sin B\sin C}+\frac{\sin(A+C)}{\sin A\sin C}+\frac{\sin(A+B)}{\sin A\sin B}\right)$$

$$=\frac{1}{2}\left(\cot B+\cot C+\cot A+\cot C+\cot A+\cot B\right)$$

$=\cot A+\cot B+\cot C$ ពិត

ដូចនេះ សមភាពត្រូវបានស្រាយបញ្ជាក់ ។

លំហាត់ទី១៦

គេឲ្យត្រីកោណ ABC មួយស្រាយថា:

$(a-b)\tan\frac{A}{2}\tan\frac{B}{2}+(b-c)\tan\frac{B}{2}\tan\frac{C}{2}+(c-a)\tan\frac{C}{2}\tan\frac{A}{2}=0$ ។

ដំណោះស្រាយ

ស្រាយថា:

$$(a-b)\tan\frac{A}{2}\tan\frac{B}{2}+(b-c)\tan\frac{B}{2}\tan\frac{C}{2}+(c-a)\tan\frac{C}{2}\tan\frac{A}{2}=0\ (*)$$

ចែក $(*)$ នឹង $\tan\frac{A}{2}\tan\frac{B}{2}\tan\frac{C}{2}$ គេបាន:

$$(a-b)\cot\frac{C}{2}+(b-c)\cot\frac{A}{2}+(c-a)\cot\frac{B}{2}=0$$

$$\frac{a-b}{\tan\frac{C}{2}}+\frac{b-c}{\tan\frac{A}{2}}+\frac{c-a}{\tan\frac{B}{2}}=0$$

យើងមាន: $a=p-b+p-c=r\left(\cot\frac{B}{2}+\cot\frac{C}{2}\right)$

$$b=p-a+p-c=r\left(\cot\frac{A}{2}+\cot\frac{C}{2}\right)$$

$$\Rightarrow a-b=r\left(\cot\frac{B}{2}-\cot\frac{A}{2}\right)$$

$$\Rightarrow (a-b)\cot\frac{C}{2} = r\cot\frac{C}{2}\left(\cot\frac{B}{2} - \cot\frac{A}{2}\right)$$

ស្រាយដូចគ្នាដែរ

$$(b-c)\cot\frac{A}{2} = r\cot\frac{A}{2}\left(\cot\frac{C}{2} - \cot\frac{B}{2}\right)$$

$$(c-a)\cot\frac{B}{2} = r\cot\frac{B}{2}\left(\cot\frac{A}{2} - \cot\frac{C}{2}\right)$$

គេបាន: $(a-b)\cot\frac{C}{2} + (b-c)\cot\frac{A}{2} + (c-a)\cot\frac{B}{2} = 0$ ពិត

ដូចនេះ សមភាពត្រូវបានស្រាយបញ្ជាក់ ។

លំហាត់ទី១៧

គេឲ្យ a,b,c ជាចំនួនពិតវិជ្ជមាន ។ ស្រាយថា:

$\sqrt{\frac{a+b}{c}} + \sqrt{\frac{b+c}{a}} + \sqrt{\frac{c+a}{b}} \geq 3\sqrt{2}$ ។

ដំណោះស្រាយ

ស្រាយថា: $\sqrt{\frac{a+b}{c}} + \sqrt{\frac{b+c}{a}} + \sqrt{\frac{c+a}{b}} \geq 3\sqrt{2}$

តាមវិសមភាព *Cauchy* ពីរដងគេបាន:

$$\sqrt{\frac{a+b}{c}} + \sqrt{\frac{b+c}{a}} + \sqrt{\frac{c+a}{b}} \geq 3\sqrt[3]{\sqrt{\left(\frac{a+b}{c}\right)\left(\frac{b+c}{a}\right)\left(\frac{c+a}{b}\right)}}$$

$$= 3\sqrt[6]{\left(\frac{a+b}{c}\right)\left(\frac{b+c}{a}\right)\left(\frac{c+a}{b}\right)} \geq 3\sqrt[6]{\frac{2^3\sqrt{ab}.\sqrt{bc}.\sqrt{ac}}{abc}} = 3\sqrt{2} \quad \text{ពិត}$$

ដូចនេះ វិសមភាពត្រូវបានស្រាយបញ្ជាក់ ។

លំហាត់ទី១៨

គេឲ្យ $\sin x+\sin y=a$ និង $\cos x+\cos y=b$ ។ គណនាតម្លៃនៃ $\tan\frac{x}{2}$ និង $\tan\frac{y}{2}$ ជាអនុគមន៍នៃ a,b ។

ដំណោះស្រាយ

គណនាតម្លៃ $\tan\frac{x}{2}$ និង $\tan\frac{y}{2}$ ជាអនុគមន៍នៃ a,b

យើងមាន: $\begin{cases}\sin x+\sin y=a\\ \cos x+\cos y=b\end{cases}$

$$\Leftrightarrow\begin{cases}2\sin\frac{x+y}{2}\cos\frac{x-y}{2}=a\ (1)\\ 2\cos\frac{x+y}{2}\cos\frac{x-y}{2}=b\,(2)\end{cases}$$

យក (1) ចៀប (2) គេបាន: $\tan\frac{x+y}{2}=\frac{a}{b}$ (3)

យក (1) និង (2) លើកជាការេរួចបូកចូលគ្នាគេបាន:

$$4\sin^2\frac{x+y}{2}\cos^2\frac{x-y}{2}+4\cos^2\frac{x+y}{2}\cos^2\frac{x-y}{2}=a^2+b^2$$

$$4\cos^2\frac{x-y}{2}=a^2+b^2 \quad (*)$$

$$\Rightarrow\left[\begin{array}{l}\cos\frac{x-y}{2}=-\frac{\sqrt{a^2+b^2}}{2}\\ \cos\frac{x-y}{2}=\frac{\sqrt{a^2+b^2}}{2}\end{array}\right.$$

ករណី $\cos\frac{x-y}{2}=-\frac{\sqrt{a^2+b^2}}{2}$ (4)

តាម (2) គេបាន: $2\left(-\frac{\sqrt{a^2+b^2}}{2}\right)\cos\frac{x+y}{2}=b$

$\Rightarrow \cos\frac{x+y}{2}=-\frac{b}{\sqrt{a^2+b^2}}$ (5)

យក $(5)-(4):\cos\frac{x+y}{2}-\cos\frac{x-y}{2}=-\frac{b}{\sqrt{a^2+b^2}}+\frac{\sqrt{a^2+b^2}}{2}$

$-2\sin\frac{x}{2}\sin\frac{y}{2}=\frac{a^2+b^2-2b}{2\sqrt{a^2+b^2}}$

$2\sin\frac{x}{2}\sin\frac{y}{2}=\frac{2b-a^2-b^2}{2\sqrt{a^2+b^2}}$ (6)

យក $(5)+(4):\cos\frac{x+y}{2}+\cos\frac{x-y}{2}=-\frac{b}{\sqrt{a^2+b^2}}-\frac{\sqrt{a^2+b^2}}{2}$

$2\cos\frac{x}{2}\cos\frac{y}{2}=-\frac{a^2+b^2+2b}{2\sqrt{a^2+b^2}}$ (7)

យក (6) ធៀប (7) គេបាន: $\tan\frac{x}{2}\tan\frac{y}{2}=\frac{a^2+b^2-2b}{a^2+b^2+2b}$ (8)

ម្យ៉ាងទៀត: $\tan\left(\frac{x}{2}+\frac{y}{2}\right)=\frac{\tan\frac{x}{2}+\tan\frac{y}{2}}{1-\tan\frac{x}{2}\tan\frac{y}{2}}$

$\Rightarrow \tan\frac{x}{2}+\tan\frac{y}{2}=\tan\frac{x+y}{2}\left(1-\tan\frac{x}{2}\tan\frac{y}{2}\right)$

$\Rightarrow \tan\frac{x}{2}+\tan\frac{y}{2}=\frac{a}{b}\left(1-\frac{a^2+b^2-2b}{a^2+b^2+2b}\right)=\frac{4a}{a^2+b^2+2b}$ (9)

តាម (8) និង (9) គេបាន $\tan\frac{x}{2}$, $\tan\frac{y}{2}$ ជាឫសនៃសមីការ:

$$X^2-\frac{4a}{a^2+b^2+2b}X+\frac{a^2+b^2-2b}{a^2+b^2+2b}=0$$

$$(a^2+b^2+2b)X^2-4aX+a^2+b^2-2b=0$$

$\Delta' = 4a^2 - (a^2 + b^2 + 2b)(a^2 + b^2 - 2b)$

$= 4a^2 - (a^2 + b^2)^2 + 4b^2$

$= 4(a^2 + b^2) - (a^2 + b^2)^2$

$= (a^2 + b^2)(4 - a^2 - b^2)$

តាម $(*) : a^2 + b^2 = 4\cos^2 \dfrac{x-y}{2} \le 4 \Rightarrow 4 - a^2 - b^2 \ge 0$

$\Rightarrow \Delta' \ge 0$

$$X = \frac{2a \pm \sqrt{(a^2 + b^2)(4 - a^2 - b^2)}}{a^2 + b^2 + 2b}$$

ករណី $\cos\dfrac{x-y}{2} = \dfrac{\sqrt{a^2 + b^2}}{2}$ ស្រាយដូចគ្នានឹងករណីខាងលើ ។

ដូចនេះតម្លៃ $\tan\dfrac{x}{2}, \tan\dfrac{y}{2}$ ដែលជាអនុគមន៍នៃ a, b កំណត់ដោយ:

$$\tan\frac{x}{2} = \frac{2a + \sqrt{(a^2 + b^2)(4 - a^2 - b^2)}}{a^2 + b^2 + 2b}$$

$$\tan\frac{y}{2} = \frac{2a - \sqrt{(a^2 + b^2)(4 - a^2 - b^2)}}{a^2 + b^2 + 2b}$$

ឬ $\tan\dfrac{x}{2} = \dfrac{2a - \sqrt{(a^2 + b^2)(4 - a^2 - b^2)}}{a^2 + b^2 + 2b}$

$$\tan\frac{y}{2} = \frac{2a + \sqrt{(a^2 + b^2)(4 - a^2 - b^2)}}{a^2 + b^2 + 2b}$$

លំហាត់ទី១៩

គេឲ្យអនុគមន៍ g ដែលកំណត់ដោយ $g(t) = t^p - t$ ស្រាយថា $g(x+a) \equiv g(x) \pmod{p}$ ចំពោះគ្រប់ចំនួនគត់វិជ្ជមាន a ។

ដំណោះស្រាយ

ស្រាយថា $g(x+a) \equiv g(x) \pmod{p}$ ចំពោះគ្រប់ចំនួនគត់វិជ្ជមាន a

យើងមាន: $g(t)=t^p-t$

$\Rightarrow g(x+a)-g(x)=(x+a)^p-(x+a)-x^p-x$

$\Leftrightarrow g(x+a)-g(x)\equiv(x+a)^p-(x+a)-x^p-x(\text{mod } p)$

$\Leftrightarrow g(x+a)-g(x)\equiv x^p+a^p-x-a-x^p-x(\text{mod } p)$

$\Leftrightarrow g(x+a)-g(x)\equiv a^p-a\equiv 0\ (\text{mod } p)\ (Fermat)$

$\Rightarrow g(x+a)\equiv g(x)(\text{mod } p)$ ពិត

ដូចនេះ $g(x+a)\equiv g(x)(\text{mod } p)$ ចំពោះគ្រប់ចំនួនគត់វិជ្ជមាន a ។

លំហាត់ទី២០

គណនាផលបូក:

$S=2.1^2C_{2015}^1+3.2^2C_{2015}^2+4.3^2C_{2015}^3+\cdots+2016.2015^2C_{2015}^{2015}$ ។

ដំណោះស្រាយ

គណនាផលបូក:

$S=2.1^2C_{2015}^1+3.2^2C_{2015}^2+4.3^2C_{2015}^3+\cdots+2016.2015^2C_{2015}^{2015}$

យើងមាន: $\sum_{k=0}^{n}(k+1)k^2C_n^k=n\sum_{k=1}^{n-1}k(k+1)C_{n-1}^{k-1}$

$=n\sum_{k=1}^{n-1}(k-1+1)(k+1)C_{n-1}^{k-1}$

$=n\sum_{k=1}^{n-1}(k-1)(k+1)C_{n-1}^{k-1}+n\sum_{k=1}^{n-1}(k+1)C_{n-1}^{k-1}$

$=n(n-1)\sum_{k=2}^{n-2}(k+1)C_{n-2}^{k-2}+n\sum_{k=1}^{n-1}(k-1+2)C_{n-1}^{k-1}$

$=n(n-1)\sum_{k=2}^{n-2}(k-2+3)C_{n-2}^{k-2}+n\sum_{k=1}^{n-1}(k-1)C_{n-1}^{k-1}+2n\sum_{k=1}^{n-1}C_{n-1}^{k-1}$

$=n(n-1)\sum_{k=2}^{n-2}(k-2)C_{n-2}^{k-2}+3n(n-1)\sum_{k=2}^{n-2}C_{n-2}^{k-2}+n(n-1)\sum_{k=2}^{n-2}C_{n-2}^{k-2}+2n\sum_{k=0}^{n-1}C_{n-1}^{k}$

$$=n(n-1)(n-2)\sum_{k=3}^{n-3}C_{n-3}^{k-3}+3n(n-1)\sum_{k=0}^{n-2}C_{n-2}^{k}+n(n-1)\sum_{k=0}^{n-2}C_{n-2}^{k}+2n.2^{n-1}$$

$$=n(n-1)(n-2)\sum_{k=0}^{n-3}C_{n-3}^{k}+3n(n-1).2^{n-2}+n(n-1).2^{n-2}+2^{n}n$$

$$=n(n-1)(n-2).2^{n-3}+3n(n-1).2^{n-2}+n(n-1).2^{n-2}+2^{n}n$$

$$=n.2^{n-3}\left[(n-1)(n-2)+6(n-1)+2(n-1)+8\right]$$

$$=n.2^{n-3}(n^2+5n+2)$$

យក $n=2015$ គេបាន៖ $S=(2015^2+5.2015+2).2015.2^{2012}$

ដូចនេះ៖ $S=(2015^2+5.2015+2).2015.2^{2012}$ ។

លំហាត់ទី២១

រកតម្លៃធំបំផុតនៃកន្សោម:

$A_{2015}=\sum_{k=0}^{2015}(k-2015x)^2x^kC_{2015}^{k}(1-x)^{2015-k}$ បើ $x\in[0,1]$ ។

ដំណោះស្រាយ

រកតម្លៃធំបំផុតនៃកន្សោម: $A_{2015}=\sum_{k=0}^{2015}(k-2015x)^2x^kC_{2015}^{k}(1-x)^{2015-k}$

បើ $x\in[0,1]$

យើងមាន:

$$A_n=\sum_{k=0}^{n}(k-nx)^2x^kC_n^k(1-x)^{n-k}$$

$$=\sum_{k=0}^{n}(k^2-2nxk+n^2x^2)x^kC_n^k(1-x)^{n-k}$$

$$=\sum_{k=0}^{n}k^2x^kC_n^k(1-x)^{n-k}-2nx\sum_{k=0}^{n}kx^kC_n^k(1-x)^{n-k}+n^2x^2\sum_{k=0}^{n}x^kC_n^k(1-x)^{n-k}\,(*)$$

តែ $\sum_{k=0}^{n} k^2 x^k C_n^k (1-x)^{n-k} = n\sum_{k=1}^{n-1} kx^k C_{n-1}^{k-1}(1-x)^{n-k}$

$= n\sum_{k=1}^{n-1}(k-1+1)x^k C_{n-1}^{k-1}(1-x)^{n-k}$

$= n\sum_{k=1}^{n-1}(k-1)x^k C_{n-1}^{k-1}(1-x)^{n-k} + n\sum_{k=1}^{n-1} x^k C_{n-1}^{k-1}(1-x)^{n-k}$

$= n(n-1)\sum_{k=2}^{n-2} x^k C_{n-2}^{k-2}(1-x)^{n-k} + nx\sum_{k=0}^{n-1} C_{n-1}^{k} x^{k-1}(1-x)^{n-k}$

$= n(n-1)x^2\sum_{k=0}^{n-2} C_{n-2}^{k} x^{k-2}(1-x)^{n-k} + nx\left[x+(1-x)\right]^{n-1}$

$= n(n-1)x^2\left[x+(1-x)\right]^{n-2} + nx$

$= n(n-1)x^2 + nx$

$= nx(nx-x+1)$

ហើយ: $\sum_{k=0}^{n} kx^k C_n^k \left(1-x\right)^{n-k} = n\sum_{k=1}^{n-1} C_{n-1}^{k-1} x^k \left(1-x\right)^{n-k}$

$= nx\sum_{k=0}^{n-1} C_{n-1}^{k} x^{k-1}(1-x)^{n-k}$

$= nx\left[x+(1-x)\right]^{n-1}$

$= nx$

ម្យ៉ាងទៀត: $\sum_{k=0}^{n} x^k C_n^k (1-x)^{n-k} = \left[x+(1-x)\right]^n = 1$

តាម $(*)$: $\mathrm{A}_n = nx(nx-x+1) - 2nx(nx) + n^2x^2$

$= n^2x^2 - nx^2 + nx - 2n^2x^2 + n^2x^2$

$= nx - nx^2$

យក $n = 2015$ គេបាន: $A_{2015} = 2015x - 2015x^2$

$\Rightarrow A'_{2015}(x) = 2015 - 4030x$

បើ $A'_{2015}(x) = 0$ គេបាន: $2015 - 4030x = 0 \Rightarrow x = \frac{1}{2}$

តារាងសញ្ញានៃ $A'_{2015}(x)$

x	0	$\frac{1}{2}$	1
$A'_{2015}(x)$	$+$	0	$-$

ដោយ $A'_{2015}(x)$ ប្តូរសញ្ញាពី $+$ ទៅ $-$ ត្រង់ $x=\frac{1}{2}$ នោះ $A_{2015}(x)$ មានតម្លៃធំបំផុតត្រង់ $x=\frac{1}{2}$ ។

តម្លៃធំបំផុតនៃ $A_{2015}(x)$ គឺ $A_{2015}\left(\frac{1}{2}\right)=2015.\frac{1}{2}-2015\left(\frac{1}{2}\right)^2=\frac{2015}{4}$

របៀបទី២

រកតម្លៃធំបំផុតនៃកន្សោម $A_{2015}=2015x-2015x^2=2015x(1-x)$

ដោយ $x\in[0,1]$ នោះ $x\geq 0,(1-x)\geq 0$ តាមវិសមភាព *Cauchy* គេបាន:

$$\sqrt{x(1-x)}\leq\frac{x+(1-x)}{2}=\frac{1}{2}\Rightarrow A_{2015}=2015x(1-x)\leq\frac{2015}{4}$$

ដូចនេះ តម្លៃធំបំផុតនៃ A_{2015} គឺ: $\frac{2015}{4}$ ។

លំហាត់ទី២២

គេឲ្យ $S_n=a^n+b^n+c^n$ ដែល $n\in\mathbb{Z}$ ។ ស្រាយថា:

$6S_{n+3}=6S_1S_{n+2}-3(S_1^2-S_2)S_{n+1}+(S_1^3-3S_1S_2+2S_3)S_n$ ។

ដំណោះស្រាយ

ស្រាយថា: $6S_{n+3}=6S_1S_{n+2}-3(S_1^2-S_2)S_{n+1}+(S_1^3-3S_1S_2+2S_3)S_n$

យើងមាន: $S_n = a^n + b^n + c^n$

$S_1 = a+b+c$

$S_1^2 = a^2+b^2+c^2+2(ab+bc+ac)$

$ab+bc+ac = \frac{1}{2}(S_1^2 - S_2)$

$a^3+b^3+c^3-3abc = (a+b+c)(a^2+b^2+c^2-ab-bc-ac)$

$S_3 - 3abc = S_1\left[S_2 - \frac{1}{2}(S_1^2 - S_2)\right] = S_1S_2 - \frac{1}{2}(S_1^3 - S_1S_2)$

$abc = \frac{1}{3}\left[S_3 - S_1S_2 + \frac{1}{2}(S_1^3 - S_1S_2)\right]$

នោះ a,b,c ជាឫសនៃសមីការ:

$X^3 - S_1X^2 + \frac{1}{2}(S_1^2 - S_2)X - \frac{1}{3}\left[S_3 - S_1S_2 + \frac{1}{2}(S_1^3 - S_1S_2)\right] = 0$

$6X^3 - 6S_1X^2 + 3(S_1^2 - S_2)\mathrm{X} - 2\left[S_3 - S_1S_2 + \frac{1}{2}(S_2S_1^3 - S_1S_2)\right] = 0$

$6X^3 = 6S_1X^2 - 3(S_1^2 - S_2)\mathrm{X} + 2S_3 - 3S_1S_2 + S_1^3 \ (*)$

ដោយ a,b,c ជាឫសនៃសមីការ $(*)$ គេបាន:

$$\begin{cases} 6a^3 = 6S_1a^2 - 3(S_1^2 - S_2)a + 2S_3 - 3S_1S_2 + S_1^3 \\ 6b^3 = 6S_1b^2 - 3(S_1^2 - S_2)b + 2S_3 - 3S_1S_2 + S_1^3 \\ 6c^3 = 6S_1c^2 - 3(S_1^2 - S_2)c + 2S_3 - 3S_1S_2 + S_1^3 \end{cases}$$

$$\begin{cases} 6a^{n+3} = 6S_1a^{n+2} - 3(S_1^2 - S_2)a^{n+1} + (2S_3 - 3S_1S_2 + S_1^3)a^n \\ 6b^{n+3} = 6S_1b^{n+2} - 3(S_1^2 - S_2)b^{n+1} + (2S_3 - 3S_1S_2 + S_1^3)b^n \\ 6c^{n+3} = 6S_1c^{n+2} - 3(S_1^2 - S_2)c^{n+1} + (2S_3 - 3S_1S_2 + S_1^3)c^n \end{cases}$$

$6S_{n+3} = 6S_1S_{n+2} - 3(S_1^2 - S_2)S_{n+1} + (S_1^3 - 3S_1S_2 + 2S_3)S_n$ ពិត

ដូចនេះ សមភាពត្រូវបានស្រាយបញ្ជាក់ ។

លំហាត់ទី២៣

គេឲ្យ a,b,c ជាចំនួនពិតដែលផ្ទៀងផ្ទាត់ថា: $2a^2+3b^2+7c^2=1$

រកតម្លៃធំបំផុតនៃអនុគមន៍ $f(a,b,c)=2013a-2014b+2015c$ ។

ដំណោះស្រាយ

រកតម្លៃធំបំផុតនៃអនុគមន៍ $f(a,b,c)=2013a-2014b+2015c$

យើងមាន: $f(a,b,c)=2013a-2014b+2015c$

$$\left[f(a,b,c)\right]^2=(2013a-2014b+2015c)^2$$

$$=\left[\frac{2013}{\sqrt{2}}\sqrt{2}a-\frac{2014}{\sqrt{3}}\sqrt{3}b+\frac{2015}{\sqrt{7}}\sqrt{7}c\right]^2$$

តាមវិសមភាព $Cauchy-swcharz$ គេបាន:

$$\left[f(a,b,c)\right]^2\le\left[\left(\frac{2013}{\sqrt{2}}\right)^2+\left(-\frac{2014}{\sqrt{3}}\right)^2+\left(\frac{2015}{\sqrt{5}}\right)^2\right](2a^2+3b^2+7c^2)$$

$$=\frac{2013^2}{2}+\frac{2014^2}{3}+\frac{2015^2}{7}$$

$$\Rightarrow f(a,b,c)\le\sqrt{\frac{2013^2}{2}+\frac{2014^2}{3}+\frac{2015^2}{7}}$$

ដូចនេះតម្លៃធំបំផុតនៃអនុគមន៍ $f(a,b,c)$ គឺ $\sqrt{\frac{2013^2}{2}+\frac{2014^2}{3}+\frac{2015^2}{7}}$

លំហាត់ទី២៤ គេឲ្យ $a_1,a_2,\ldots,a_n$ ជាចំនួនពិតដែលផ្ទៀងផ្ទាត់ $a_1+a_2+\cdots+a_n\ge n^2$ និង $a_1^2+a_2^2+\cdots+a_n^2\le n^3+1$ ។ ស្រាយថា: $n-1\le a_k\le n+1$ ចំពោះគ្រប់ចំនួនគត់វិជ្ជមាន $k\le n$ ។

ដំណោះស្រាយ

ស្រាយថា: $n-1 \le a_k \le n+1$ ចំពោះគ្រប់ចំនួនគត់វិជ្ជមាន $k \le n$

យើងត្រូវស្រាយថា: $-1 \le a_k - n \le 1$ ឬ $|a_k - n| \le 1$

យើងមាន: $\sum_{k=1}^{n}(a_k-n)^2 = \sum_{k=1}^{n} a_k^2 - 2n\sum_{k=1}^{n} a_k + n^3$

ដោយ: $a_1 + a_2 + \cdots + a_n \ge n^2$ និង $a_1^2 + a_2^2 + \cdots + a_n^2 \le n^3 + 1$

$\Rightarrow \sum_{k=1}^{n}(a_k-n)^2 \le n^3 + 1 - 2n.n^2 + n^3 = 1$

$\Rightarrow (a_k - n)^2 \le 1$

$\Rightarrow |a_k - n| \le 1$ ពិត

ដូចនេះ វិសមភាពត្រូវបានស្រាយបញ្ជាក់ ។

លំហាត់ទី២៥

គេឲ្យ x_1, x_2, x_3 ជាឫសនៃសមីការ $x^3 + ax^2 + x + b = 0, (b \ne 0)$ ។

ស្រាយថា:

$$\left(x_1-\frac{1}{x_1}\right)\left(x_2-\frac{1}{x_2}\right)+\left(x_2-\frac{1}{x_2}\right)\left(x_3-\frac{1}{x_3}\right)+\left(x_3-\frac{1}{x_3}\right)\left(x_1-\frac{1}{x_1}\right)=4$$

ដំណោះស្រាយ

ស្រាយថា:

$$\left(x_1-\frac{1}{x_1}\right)\left(x_2-\frac{1}{x_2}\right)+\left(x_2-\frac{1}{x_2}\right)\left(x_3-\frac{1}{x_3}\right)+\left(x_3-\frac{1}{x_3}\right)\left(x_1-\frac{1}{x_1}\right)=4$$

យើងមាន:

$$\left(x_1-\frac{1}{x_1}\right)\left(x_2-\frac{1}{x_2}\right)+\left(x_2-\frac{1}{x_2}\right)\left(x_3-\frac{1}{x_3}\right)+\left(x_3-\frac{1}{x_3}\right)\left(x_1-\frac{1}{x_1}\right)=4$$

$$\Leftrightarrow x_1x_2x_3(x_1x_2+x_2x_3+x_1x_3)-(x_1+x_2+x_3)(x_1x_2+x_2x_3+x_1x_3)$$

$$+x_1+x_2+x_3=x_1x_2x_3\ (*)$$

ដោយ x_1,x_2,x_3 ជាឫសនៃសមីការ $x^3+ax^2+x+b=0,(b\neq 0)$

តាមទ្រឹស្ដីបទវ្យែតគេបាន: $\begin{cases}x_1+x_2+x_3=-a\\ x_1x_2+x_2x_3+x_1x_3=1\\ x_1x_2x_3=-b\end{cases}$

តាមទំនាក់ទំនង (*) គេបាន: $-b+a-a=-b$ ពិត

ដូចនេះ សមភាពត្រូវបានស្រាយបញ្ជាក់ ។

លំហាត់ទី២៦

គេឲ្យត្រីកោណ ABC មួយ។ស្រាយបញ្ជាក់សមភាពខាងក្រោម:

$$\frac{1}{\sin A}+\frac{1}{\sin B}+\frac{1}{\sin C}=\frac{1}{2}\left(\tan\frac{A}{2}+\tan\frac{B}{2}+\tan\frac{C}{2}+\cot\frac{A}{2}\cot\frac{B}{2}\cot\frac{C}{2}\right)$$

ដំណោះស្រាយ

ស្រាយបញ្ជាក់សមភាព:

$$\frac{1}{\sin A}+\frac{1}{\sin B}+\frac{1}{\sin C}=\frac{1}{2}\left(\tan\frac{A}{2}+\tan\frac{B}{2}+\tan\frac{C}{2}+\cot\frac{A}{2}\cot\frac{B}{2}\cot\frac{C}{2}\right)$$

យើងមាន: $\tan\frac{A}{2}+\cot\frac{A}{2}=\dfrac{\sin\frac{A}{2}}{\cos\frac{A}{2}}+\dfrac{\cos\frac{A}{2}}{\sin\frac{A}{2}}=\dfrac{2}{\sin A}$

ស្រាយដូចគ្នាដែរ: $\tan\frac{B}{2}+\cot\frac{B}{2}=\dfrac{2}{\sin B}$, $\tan\frac{C}{2}+\cot\frac{C}{2}=\dfrac{2}{\sin C}$

បូកសមភាពទាំងអស់បញ្ចូលគ្នាគេបាន:

$$\tan\frac{A}{2}+\tan\frac{B}{2}+\tan\frac{C}{2}+\cot\frac{A}{2}+\cot\frac{B}{2}+\cot\frac{C}{2}$$

$$=2\left(\frac{1}{\sin A}+\frac{1}{\sin B}+\frac{1}{\sin C}\right)$$

តែម្យ៉ាងទៀត: $\cot\frac{A}{2}+\cot\frac{B}{2}+\cot\frac{C}{2}=\cot\frac{A}{2}\cot\frac{B}{2}\cot\frac{C}{2}$ គេបាន:

$$\frac{1}{\sin A}+\frac{1}{\sin B}+\frac{1}{\sin C}=\frac{1}{2}\left(\tan\frac{A}{2}+\tan\frac{B}{2}+\tan\frac{C}{2}+\cot\frac{A}{2}\cot\frac{B}{2}\cot\frac{C}{2}\right)$$

ដូចនេះ សមភាពត្រូវបានស្រាយបញ្ជាក់ ។

លំហាត់ទី២៧

ស្រាយបញ្ជាក់សមភាព: $\tan\frac{3\pi}{11}+4\sin\frac{2\pi}{11}=\sqrt{11}$ ។

ដំណោះស្រាយ

ស្រាយបញ្ជាក់សមភាព: $\tan\frac{3\pi}{11}+4\sin\frac{2\pi}{11}=\sqrt{11}$

តាង: $a=\frac{\pi}{11}$ យើងត្រូវស្រាយថា: $\tan 3a+4\sin 2a=\sqrt{11}$

យើងមាន: $\tan 3a+4\sin 2a=\sqrt{11}$

$$\sin 3a+4\sin 2a\cos 3a=\sqrt{11}\cos 3a$$

$$\sin 3a+2\sin 5a-2\sin a=\sqrt{11}\cos 3a$$

$$\Leftrightarrow \sin^2 3a+4\sin^2 5a+4\sin^2 a+4\sin 3a\sin 5a$$
$$-4\sin 3a\sin a-8\sin a\sin 5a=11\cos^2 3a$$

$$\Leftrightarrow \frac{1-\cos 6a}{2}+4\cdot\frac{1-\cos 10a}{2}+4\cdot\frac{1-\cos 2a}{2}+2(\cos 2a-\cos 8a)$$

$$-2(\cos 2a-\cos 4a)-4(\cos 4a-\cos 6a)=11\cdot\frac{1+\cos 6a}{2}$$

$$\Leftrightarrow 1-\cos 6a+4-4\cos 10a+4-4\cos 2a+4\cos 2a-4\cos 8a$$
$$-4\cos 2a+4\cos 4a-8\cos 4a+8\cos 6a=11+11\cos 6a$$

$$\Leftrightarrow -4\cos 2a-4\cos 4a-4\cos 6a-4\cos 8a-4\cos 10a=2$$
$$\Leftrightarrow 2\cos 2a+2\cos 4a+2\cos 6a+2\cos 8a+2\cos 10a=-1$$

$$\Leftrightarrow 2\cos 2a\sin a+2\cos 4a\sin a+2\cos 6a\sin a$$
$$+2\cos 8a\sin a+2\cos 10a\sin a=-\sin a$$
$$\Leftrightarrow (\sin 3a-\sin a)+(\sin 5a-\sin 3a)+(\sin 7a-\sin 5a)$$
$$+(\sin 9a-\sin 7a)+(\sin 11a-\sin 9a)=-\sin a$$

$$\Leftrightarrow \sin 11a=0\Leftrightarrow \sin 11.\frac{\pi}{11}=0\Leftrightarrow \sin\pi=0$$ ពិត

ដូចនេះ សមភាពត្រូវបានស្រាយបញ្ជាក់ ។

លំហាត់ទី២៨

គេឲ្យស្វ៊ីត $(Febonacci)$ កំណត់ដោយ: $F_1=F_2=1$ និង

$F_{n+1}=F_n+F_{n-1}, n\ge 2$ ស្រាយថា: $F_n=\frac{1}{\sqrt{5}}\left[\left(\frac{1+\sqrt{5}}{2}\right)^n-\left(\frac{1-\sqrt{5}}{2}\right)^n\right]$

ដំណោះស្រាយ

ស្រាយថា: $F_n=\frac{1}{\sqrt{5}}\left[\left(\frac{1+\sqrt{5}}{2}\right)^n-\left(\frac{1-\sqrt{5}}{2}\right)^n\right]$

យើងមាន: $F_{n+1}=F_n+F_{n-1}$ មានសមីការសម្គាល់: $x^2-x-1=0$

មានឫស: $x=\frac{1+\sqrt{5}}{2}, x=\frac{1-\sqrt{5}}{2}$ គេបាន:

$F_n=A\left(\frac{1+\sqrt{5}}{2}\right)^n+B\left(\frac{1-\sqrt{5}}{2}\right)^n$ តែដោយ $F_1=F_2=1$ គេបាន:

$$\begin{cases} F_1 = A\left(\frac{1+\sqrt{5}}{2}\right) + B\left(\frac{1-\sqrt{5}}{2}\right) = 1 \\ F_2 = A\left(\frac{1+\sqrt{5}}{2}\right)^2 + B\left(\frac{1-\sqrt{5}}{2}\right)^2 = 1 \end{cases}$$

$$\Leftrightarrow \begin{cases} A(1+\sqrt{5}) + B(1-\sqrt{5}) = 2 \ (1) \\ A(3+\sqrt{5}) + B(3-\sqrt{5}) = 2 \ (2) \end{cases}$$

$$\Leftrightarrow \begin{cases} A(1+\sqrt{5})(3-\sqrt{5}) + B(1-\sqrt{5})(3-\sqrt{5}) = 2(3-\sqrt{5}) \\ A(3+\sqrt{5})(1-\sqrt{5}) + B(3-\sqrt{5})(1-\sqrt{5}) = 2(1-\sqrt{5}) \end{cases}$$

$$A\left[(-2+2\sqrt{5}) - (-2-2\sqrt{5})\right] = 4$$

$$A.4\sqrt{5} = 4 \Rightarrow A = \frac{1}{\sqrt{5}}$$

$$(1): \frac{1}{\sqrt{5}}(1+\sqrt{5}) + B(1-\sqrt{5}) = 2$$

$$\Leftrightarrow 1+\sqrt{5} + B(\sqrt{5}-5) = 2\sqrt{5}$$

$\Rightarrow B = \frac{\sqrt{5}-1}{\sqrt{5}-5} = -\frac{1}{\sqrt{5}}$ គេបាន: $F_n = \frac{1}{\sqrt{5}}\left[\left(\frac{1+\sqrt{5}}{2}\right)^n - \left(\frac{1-\sqrt{5}}{2}\right)^n\right]$ ពិត

ដូចនេះ $F_n = \frac{1}{\sqrt{5}}\left[\left(\frac{1+\sqrt{5}}{2}\right)^n - \left(\frac{1-\sqrt{5}}{2}\right)^n\right]$ ។ (ទ្រឹស្តីបទ *Binet*)

លំហាត់ទី២៩

គេឲ្យស្វីត $(Febonacci)$ កំណត់ដោយ: $F_1 = F_2 = 1$ និង $F_{n+1} = F_n + F_{n-1}, n \geq 2$ ស្រាយថា: $F_{n-1}F_{n+1} = F_n^2 + (-1)^n$ ។

ដំណោះស្រាយ

ស្រាយថា: $F_{n-1}F_{n+1}=F_n^2+(-1)^n$

តាមទ្រឹស្តីបទ *Binet* តាង $a=\dfrac{1+\sqrt{5}}{2}$ និង $b=\dfrac{1-\sqrt{5}}{2}$ គេបាន:

$F_n=\dfrac{1}{\sqrt{5}}(a^n-b^n)$ ហើយ $\begin{cases}a-b=\sqrt{5}, a+b=1\\ ab=-1\end{cases}$

$$\Rightarrow F_{n-1}=\frac{1}{\sqrt{5}}(a^{n-1}-b^{n-1})$$

$$\Rightarrow F_{n+1}=\frac{1}{\sqrt{5}}(a^{n+1}-b^{n+1})$$

$$\Rightarrow F_{n-1}.F_{n+1}=\frac{1}{5}\left[(a^{n-1}-b^{n-1})(a^{n+1}-b^{n+1})\right]$$

$$=\frac{1}{5}(a^{2n}-a^{n-1}b^{n+1}-a^{n+1}b^{n-1}+b^{2n})$$

$$=\frac{1}{5}\left[a^{2n}+b^{2n}-(ab)^{n-1}(a^2+b^2)\right]$$

$$=\frac{1}{5}\left[(a^n-b^n)^2+2a^nb^n-(ab)^{n-1}\left((a+b)^2-2ab\right)\right]$$

តែ $ab=\left(\dfrac{1+\sqrt{5}}{2}\right)\left(\dfrac{1-\sqrt{5}}{2}\right)=-1$ និង $a+b=\dfrac{1+\sqrt{5}}{2}+\dfrac{1-\sqrt{5}}{2}=1$

យើងបាន:

$F_{n-1}F_{n+1}=\left[\dfrac{1}{\sqrt{5}}(a^n-b^n)\right]^2+\dfrac{1}{5}\left[2(-1)^n-3(-1)^{n-1}\right]=F_n^2+(-1)^n$ ពិត

ដូចនេះ: $F_{n-1}F_{n+1}=F_n^2+(-1)^n$ ។ (ទ្រឹស្តីបទ *Cassini*)

លំហាត់ទី៣០

គេឲ្យស្វ៊ីត (*Febonacci*) កំណត់ដោយ: $F_1=F_2=1$ និង $F_{n+1}=F_n+F_{n-1}, n\geq 2$ ស្រាយថា: $F_{m+n+1}=F_{n+1}F_{m+1}+F_mF_n\ , m\in\mathbb{N}$

ដំណោះស្រាយ

ស្រាយថា: $F_{m+n+1} = F_{n+1}F_{m+1} + F_m F_n \ , m \in \mathbb{N}$

តាមទ្រឹស្តីបទ *Binet* តាង $a = \frac{1+\sqrt{5}}{2}$ និង $b = \frac{1-\sqrt{5}}{2}$ គេបាន:

$$F_n = \frac{1}{\sqrt{5}}(a^n - b^n)$$

$$\Rightarrow F_{n+1}F_{m+1} + F_n F_m = \frac{1}{5}(a^{n+1} - b^{n+1})(a^{m+1} - b^{m+1}) + \frac{1}{5}(a^n - b^n)(a^m - b^m)$$

$$= \frac{1}{5}(a^{m+n+2} - a^{n+1}b^{m+1} - a^{m+1}b^{n+1} + b^{m+n+2} + a^{n+m} - a^n b^m - a^m b^n + b^{n+m})$$

$$= \frac{1}{5}\left[a^{m+n+2} + b^{m+n+2} + a^{n+m} + b^{n+m} - a^n b^m(ab+1) - a^m b^n(ab+1)\right]$$

តែ $ab = \left(\frac{1+\sqrt{5}}{2}\right)\left(\frac{1-\sqrt{5}}{2}\right) = -1$ គេបាន:

$$F_{n+1}F_{m+1} + F_n F_m = \frac{1}{5}(a^{m+n+2} + b^{m+n+2} + a^{n+m} + b^{n+m})$$

$$= \frac{1}{5}(a^{m+n}.a^2 + b^{m+n}.b^2 + a^{m+n} + b^{n+m})$$

$$= \frac{1}{5}\left[\left(\frac{1+\sqrt{5}}{2}\right)^2 a^{m+n} + \left(\frac{1-\sqrt{5}}{2}\right)^2 b^{m+n} + a^{m+n} + b^{n+m}\right]$$

$$= \frac{1}{5}\left[a^{m+n}\left(\frac{6+2\sqrt{5}}{4} + 1\right) + b^{m+n}\left(\frac{6-2\sqrt{5}}{4} + 1\right)\right]$$

$$= \frac{1}{5}\left[a^{m+n}\left(\frac{\sqrt{5}+5}{2}\right) + b^{m+n}\left(\frac{5-\sqrt{5}}{2}\right)\right]$$

$$= \frac{1}{\sqrt{5}}\left[a^{m+n}\left(\frac{1+\sqrt{5}}{2}\right) - b^{m+n}\left(\frac{1-\sqrt{5}}{2}\right)\right]$$

$$= \frac{1}{\sqrt{5}}(a^{n+m+1} - b^{n+m+1}) = F_{n+m+1}$$ ពិត

ដូចនេះ $F_{m+n+1} = F_{n+1}F_{m+1} + F_mF_n \ , m \in \mathbb{N}$ ។

លំហាត់ទី៣១

គេឲ្យស្វ៊ីត $(Febonacci)$ កំណត់ដោយ: $F_1 = F_2 = 1$ និង $F_{n+1} = F_n + F_{n-1}, n \geq 2$ ស្រាយថាចំពោះគ្រប់ n,k ជាចំនួនគត់ធម្មជាតិនោះប្រភាគ $\frac{kF_{n+2}+F_n}{kF_{n+3}+F_{n+1}}$ សម្រួលមិនបាន ។

ដំណោះស្រាយ

ស្រាយថាចំពោះគ្រប់ n,k ជាចំនួនគត់ធម្មជាតិនោះប្រភាគ $\frac{kF_{n+2}+F_n}{kF_{n+3}+F_{n+1}}$ សម្រួលមិនបាន

តាង $d = GCD(kF_{n+2} + F_n, \mathrm{F}_{n+3} + F_{n+1})$

ដោយ $d \in \mathbb{N}$ ដើម្បីស្រាយថាប្រភាគ $\frac{kF_{n+2}+F_n}{kF_{n+3}+F_{n+1}}$ សម្រួលមិនបាន

យើងត្រូវស្រាយថា: $d = 1$ ។

$$\begin{cases} d \,|\, (kF_{n+2} + F_n) & (1) \\ d \,|\, (kF_{n+3} + F_{n+1}) & (2) \end{cases} \Rightarrow d \,\big|\, \left[k(\mathrm{F}_{n+3} - F_{n+2}) + F_{n+1} - F_n \right]$$

$$\Leftrightarrow d \,|\, (kF_{n+1} + F_{n-1}) \ (3)$$

$$(1)-(3): \Rightarrow d \,\big|\, \left[k(\mathrm{F}_{n+2} - F_{n+1}) + F_n - F_{n-1} \right]$$

$$\Leftrightarrow d \,|\, (kF_n + F_{n-2})$$

ធ្វើតាមលំនាំនេះគេបាន:

$$\begin{cases} d \,|\, (kF_3 + F_1) \\ d \,|\, (kF_4 + F_2) \end{cases} \Leftrightarrow \begin{cases} d \,\big|\, \left[k(\mathrm{F}_2 + F_1) + F_1 \right] \\ d \,\big|\, \left[k(2F_2 + F_1) + F_2 \right] \end{cases} \Leftrightarrow \begin{cases} d \,|\, 2k+1 \\ d \,|\, 3k+1 \end{cases}$$

$$\begin{cases} d \mid 6k+3 \ (*) \\ d \mid 6k+2 \ (**) \end{cases} \Leftrightarrow (*)-(**): d \mid 1$$

ដោយ $d \in \mathbb{N}$ គេបាន: $d=1$

ដូចនេះប្រភាគ $\dfrac{kF_{n+2}+F_n}{kF_{n+3}+F_{n+1}}$ សម្រួលមិនបាន ។

លំហាត់ទី៣២

គេឲ្យស្ទីត $(Febonacci)$ កំណត់ដោយ: $F_1 = F_2 = 1$ និង $F_{n+1} = F_n + F_{n-1}, n \geq 2$ ស្រាយថា: $F_1 + F_2 + \cdots + F_n = F_{n+2} - 1$ ។

ដំណោះស្រាយ

ស្រាយថា: $F_1 + F_2 + \cdots + F_n = F_{n+2} - 1$

យើងមាន: $F_{n+1} = F_n + F_{n-1}$

$\Rightarrow F_{n+1} - F_n = F_{n-1}$

$$\Rightarrow \sum_{k=2}^{n+1} (F_{k+1} - F_k) = \sum_{k=2}^{n+1} F_{k-1}$$

$$\Leftrightarrow F_{n+2} - F_2 = \sum_{k=1}^{n} F_k = F_1 + F_2 + \cdots + F_n$$

$\Leftrightarrow F_1 + F_2 + \cdots + F_n = F_{n+2} - 1 \ ;(F_2 = 1)$ ពិត

ដូចនេះ $F_1 + F_2 + \cdots + F_n = F_{n+2} - 1$ ត្រូវបានស្រាយបញ្ជាក់ ។

លំហាត់ទី៣៣ គេឲ្យស្ទីត $(Febonacci)$ កំណត់ដោយ: $F_1 = F_2 = 1$ និង $F_n = F_{n-1} + F_{n-2}, n \geq 3$ ។ តាង $Q = \begin{pmatrix} 1 & 1 \\ 1 & 0 \end{pmatrix}$ ស្រាយថា:

$Q^n = \begin{pmatrix} F_{n+1} & F_n \\ F_n & F_{n-1} \end{pmatrix}, n \geq 2$ រួចទាញថា: $F_{3n} = F_{n+1}^3 + F_n^3 - F_{n-1}^3, n \geq 1$

ដំណោះស្រាយ

ស្រាយថា: $Q^n = \begin{pmatrix} F_{n+1} & F_n \\ F_n & F_{n-1} \end{pmatrix}$ $, n \ge 2$ រួចទាញថា:

$F_{3n} = F_{n+1}^3 + F_n^3 - F_{n-1}^3$ $, n \ge 1$

យើងមាន: $Q = \begin{pmatrix} 1 & 1 \\ 1 & 0 \end{pmatrix}$

យើងនឹងស្រាយតាមវាចាអនុមានរួមគណិតវិទ្យាចំពោះ $n = 2$

យើងបាន: $Q^2 = Q.Q = \begin{pmatrix} 1 & 1 \\ 1 & 0 \end{pmatrix}\begin{pmatrix} 1 & 1 \\ 1 & 0 \end{pmatrix} = \begin{pmatrix} 2 & 1 \\ 1 & 1 \end{pmatrix} = \begin{pmatrix} F_3 & F_2 \\ F_2 & F_1 \end{pmatrix}$ ពិត

ឧបមាថាវាពិតដល់ $n = k$ ដែល: $Q^k = \begin{pmatrix} F_{k+1} & F_k \\ F_k & F_{k-1} \end{pmatrix}$

យើងនឹងបន្តស្រាយថាវាពិតដល់ $n = k+1$ ដែល: $Q^{k+1} = \begin{pmatrix} F_{k+2} & F_{k+1} \\ F_{k+1} & F_k \end{pmatrix}$

យើងមាន: $Q^{k+1} = Q.Q^k = \begin{pmatrix} 1 & 1 \\ 1 & 0 \end{pmatrix}\begin{pmatrix} F_{k+1} & F_k \\ F_k & F_{k-1} \end{pmatrix}$

$= \begin{pmatrix} F_{k+1} + F_k & F_k + F_{k-1} \\ F_{k+1} & F_k \end{pmatrix}$ តែ $F_n = F_{n-1} + F_{n-2}$ គេបាន:

$F_{k+1} + F_k = F_{k+2}$, $F_k + F_{k-1} = F_{k+1}$ យើងបាន: $Q^{k+1} = \begin{pmatrix} F_{k+2} & F_{k+1} \\ F_{k+1} & F_k \end{pmatrix}$ ពិត

ដូចនេះ $Q^n = \begin{pmatrix} F_{n+1} & F_n \\ F_n & F_{n-1} \end{pmatrix}$ $, n \ge 2$ ត្រូវបានស្រាយបញ្ជាក់ ។

ស្រាយថា: $F_{3n} = F_{n+1}^3 + F_n^3 - F_{n-1}^3$ $, n \ge 1$

យើងមាន: $Q^n = \begin{pmatrix} F_{n+1} & F_n \\ F_n & F_{n-1} \end{pmatrix} \Rightarrow Q^{3n} = \begin{pmatrix} F_{3n+1} & F_{3n} \\ F_{3n} & F_{3n-1} \end{pmatrix}$

ម្យ៉ាងទៀត $Q^{3n} = Q^n.Q^n.Q^n = \begin{pmatrix} F_{n+1} & F_n \\ F_n & F_{n-1} \end{pmatrix}\begin{pmatrix} F_{n+1} & F_n \\ F_n & F_{n-1} \end{pmatrix}\begin{pmatrix} F_{n+1} & F_n \\ F_n & F_{n-1} \end{pmatrix}$

$$=\begin{pmatrix} F_{n+1}^2+F_n^2 & F_nF_{n+1}+F_{n-1}F_n \\ F_nF_{n+1}+F_{n-1}F_n & F_n^2+F_{n-1}^2 \end{pmatrix}\begin{pmatrix} F_{n+1} & F_n \\ F_n & F_{n-1} \end{pmatrix}$$

$$=\begin{pmatrix} F_{n+1}^3+F_n^2F_{n+1}+F_{n+1}F_n^2+F_n^2F_{n-1} & F_{n+1}^2F_n+F_n^3+F_{n+1}F_nF_{n-1}+F_nF_{n-1}^2 \\ F_nF_{n+1}^2+F_{n-1}F_nF_{n+1}+F_n^3+F_{n-1}^2F_n & F_n^2F_{n+1}+F_{n-1}F_n^2+F_n^2F_{n-1}+F_{n-1}^3 \end{pmatrix}$$

គេបាន: $F_{3n}=F_nF_{n+1}^2+F_{n-1}F_nF_{n+1}+F_n^3+F_{n-1}^2F_n$

$=F_nF_{n+1}(F_{n+1}+F_{n-1})+F_n^3+F_{n-1}^2F_n$

$=F_{n+1}(F_{n+1}-F_{n-1})(F_{n+1}+F_{n-1})+F_n^3+F_{n-1}^2F_n$

$=F_{n+1}(F_{n+1}^2-F_{n-1}^2)+F_n^3+F_{n-1}^2F_n$

$=F_{n+1}^3+F_n^3-F_{n+1}F_{n-1}^2+F_{n-1}^2F_n$

$=F_{n+1}^3+F_n^3-F_{n-1}^2(F_{n+1}-F_n)$

$=F_{n+1}^3+F_n^3-F_{n-1}^3$ ពិត

ដូចនេះ $F_{3n}=F_{n+1}^3+F_n^3-F_{n-1}^3\ ,n\geq 1$ ត្រូវបានស្រាយបញ្ជាក់។

លំហាត់ទី៣៤

គេឲ្យស្វ៊ីត $(Febonacci)$ កំណត់ដោយ: $F_1=F_2=1$ និង $F_{n+1}=F_n+F_{n-1}\,,n\geq 2$ ស្រាយថាបញ្ជាក់ថា: $F_{2n}=F_{n+1}^2-F_{n-1}^2$ ។

ដំណោះស្រាយ

ស្រាយថាបញ្ជាក់ថា: $F_{2n}=F_{n+1}^2-F_{n-1}^2$

តាមទ្រឹស្តីបទ $Binet$ តាង $a=\dfrac{1+\sqrt{5}}{2}$ និង $b=\dfrac{1-\sqrt{5}}{2}$ គេបាន:

$F_n=\dfrac{1}{\sqrt{5}}(a^n-b^n)$ ហើយ $\begin{cases} a-b=\sqrt{5}, a+b=1 \\ ab=-1 \end{cases}$

$$\Rightarrow F_{n+1}^2-F_{n-1}^2=\left[\frac{1}{\sqrt{5}}(a^{n+1}-b^{n+1})\right]^2-\left[\frac{1}{\sqrt{5}}(a^{n-1}-b^{n-1})\right]^2$$

$$=\frac{1}{5}(a^{2n+2}-2a^{n+1}b^{n+1}+b^{2n+2}-a^{2n-2}+2a^{n-1}b^{n-1}-b^{2n-2})$$

$$=\frac{1}{5}\left[a^{2n+2}+b^{2n+2}-a^{2n-2}-b^{2n-2}-2(-1)^{n+1}+2(-1)^{n-1}\right]$$

$$=\frac{1}{5}(a^{2n}.a^{2}+b^{2n}.b^{2}-a^{2n}.a^{-2}-b^{2n}.b^{-2})$$

$$=\frac{1}{5}\left[a^{2n}\left(\frac{1+\sqrt{5}}{2}\right)^{2}+b^{2n}\left(\frac{1-\sqrt{5}}{2}\right)^{2}-a^{2n}\left(\frac{2}{1+\sqrt{5}}\right)^{2}-b^{2n}\left(\frac{2}{1-\sqrt{5}}\right)^{2}\right]$$

$$=\frac{1}{5}\left[a^{2n}\left(\frac{3+\sqrt{5}}{2}-\frac{2}{3+\sqrt{5}}\right)+b^{2n}\left(\frac{3-\sqrt{5}}{2}-\frac{2}{3-\sqrt{5}}\right)\right]$$

$$=\frac{1}{5}\left[a^{2n}\left(\frac{(3+\sqrt{5})-(3-\sqrt{5})}{2}\right)+b^{2n}\left(\frac{(3-\sqrt{5})-(3+\sqrt{5})}{2}\right)\right]$$

$$=\frac{1}{\sqrt{5}}(a^{2n}-b^{2n})=F_{2n}$$ ពិត

ដូចនេះ $F_{2n}=F_{n+1}^{2}-F_{n-1}^{2}$ ត្រូវបានស្រាយបញ្ជាក់ ។

លំហាត់ទី៣៩

គេឲ្យស្វ៊ីត $(Febonacci)$ កំណត់ដោយ: $F_1=F_2=1$ និង $F_{n+1}=F_n+F_{n-1}\,,n\ge 2$

ស្រាយថា: $F_{2n}F_{n-1}-F_{2n-1}F_n=(-1)^nF_n\,,n\ge 1$ ។

ដំណោះស្រាយ

ស្រាយថា: $F_{2n}F_{n-1}-F_{2n-1}F_n=(-1)^nF_n\,,n\ge 1$ រួចគណនា: $\sum_{n=0}^{\infty}\frac{1}{F_{2^n}}$

តាមទ្រឹស្តីបទ $Binet$ តាង $a=\frac{1+\sqrt{5}}{2}$ និង $b=\frac{1-\sqrt{5}}{2}$ គេបាន:

$F_n = \frac{1}{\sqrt{5}}(a^n - b^n)$ ហើយ $\begin{cases} a-b=\sqrt{5}, a+b=1 \\ ab=-1 \end{cases}$

យើងបាន: $F_{2n}F_{n-1} - F_{2n-1}F_n$

$= \frac{1}{5}(a^{2n} - b^{2n})(a^{n-1} - b^{n-1}) - \frac{1}{5}(a^{2n-1} - b^{2n-1})(a^n - b^n)$

$= \frac{1}{5}\left[a^{3n-1} - a^{2n}b^{n-1} - a^{n-1}b^{2n} + b^{3n-1} - (a^{3n-1} - a^{2n-1}b^n - a^n b^{2n-1} + b^{3n-1})\right]$

$= \frac{1}{5}(a^{n-1}b^{2n-1} + a^{2n-1}b^n - a^{2n}b^{n-1} - a^{n-1}b^{2n})$

$= \frac{1}{5}\left[a^{n-1}b^{2n-1}(a-b) + a^{2n-1}b^{n-1}(b-a)\right]$

$= \frac{1}{5}(\sqrt{5}a^{n-1}b^{2n-1} - \sqrt{5}a^{2n-1}b^{n-1})$

$= \frac{1}{\sqrt{5}}(a^{n-1}b^{2n-1} - a^{2n-1}b^{n-1})$

$= \frac{1}{\sqrt{5}}\left[a^n b^n \left(\frac{1}{ab}\cdot b^n - \frac{1}{ab}\cdot a^n\right)\right]$

$= a^n b^n \frac{1}{\sqrt{5}}(a^n - b^n)$

$= (-1)^n F_n$ ពិត

ដូចនេះ $F_{2n}F_{n-1} - F_{2n-1}F_n = (-1)^n F_n, n \geq 1$ ត្រូវបានស្រាយបញ្ជាក់ ។

ខ្ញុំដើរយឺត តែខ្ញុំមិនដើរថយក្រោយ

លំហាត់ទី៣៦

គេឲ្យ $f:\mathbb{N}^* \to \mathbb{R}$ ផ្ទៀងផ្ទាត់លក្ខខណ្ឌខាងក្រោម:

$f(n+2)=f(n+1)-f(n)\ ;\ f(1)=1\ ,\ f(2)=0$

បង្ហាញថា: $|f(n)| \le \dfrac{2\sqrt{3}}{3}\ ,\ \forall n \in \mathbb{N}^*$ ។

ដំណោះស្រាយ

បង្ហាញថា: $|f(n)| \le \dfrac{2\sqrt{3}}{3}\ ,\ \forall n \in \mathbb{N}^*$

យើងមាន: $f(n+2)=f(n+1)-f(n)\ ;\ f(1)=1\ ,\ f(2)=0$

តាង $f(n)=u_n$ គេបាន $u_{n+2}=u_{n+1}-u_n\ ;\ u_1=f(1)=1\ ,\ u_2=f(2)=0$

សមីការសម្គាល់នៃស្វ៊ីតគឺ $\lambda^2-\lambda+1=0$ មានឫសពីរជាចំនួនកុំផ្លិច

$\lambda_1=\dfrac{1+i\sqrt{3}}{2}\ ,\ \lambda_2=\dfrac{1-i\sqrt{3}}{2}$

ដោយ $\lambda=\cos\dfrac{\pi}{3}\pm i\sin\dfrac{\pi}{3}$ គេបាន: $u_n=f(n)=A\cos\dfrac{n\pi}{3}+B\sin\dfrac{n\pi}{3}$

ដែល A, B ជាចំនួនថេរដែលត្រូវរក ។

យើងមាន: $\begin{cases} 1=u_1=A\cos\dfrac{\pi}{3}+B\sin\dfrac{\pi}{3} \\ 0=u_2=A\cos\dfrac{2\pi}{3}+B\sin\dfrac{2\pi}{2} \end{cases}$

$$\Leftrightarrow \begin{cases} \dfrac{1}{2}A+\dfrac{\sqrt{3}}{2}B=1 \quad (1) \\ -\dfrac{1}{2}A+\dfrac{\sqrt{3}}{2}B=0 \quad (2) \end{cases}$$

យក $(1)+(2)$ គេបាន: $B=\dfrac{\sqrt{3}}{3}$ ហើយ $A=1$ ។

យើងបាន: $f(n)=\cos\dfrac{n\pi}{3}+\dfrac{\sqrt{3}}{3}\sin\dfrac{n\pi}{3}$

តាមវិសមភាព $Cauchy-Schwarz$ គេបាន:

$$|f(n)|=\left|\cos\frac{n\pi}{3}+\frac{\sqrt{3}}{3}\sin\frac{n\pi}{3}\right|\le\sqrt{\left(1^2+\left(\frac{\sqrt{3}}{3}\right)^2\right)\left(\cos^2\frac{n\pi}{3}+\sin^2\frac{n\pi}{3}\right)}$$

ឬ $|f(n)|\le\sqrt{1+\dfrac{3}{9}}=\dfrac{2\sqrt{3}}{3}$ ពិត

ដូចនេះ $|f(n)|\le\sqrt{1+\dfrac{3}{9}}=\dfrac{2\sqrt{3}}{3}$ ។

លំហាត់ទី៣៧

អនុគមន៍ $f:\mathbb{R}\to\mathbb{R}$ ហើយផ្ទៀងផ្ទាត់លក្ខខណ្ឌ

$f\left(x^2+x+3\right)+2f\left(x^2-3x+5\right)=6x^2-10x+7\ ,\ \forall x\in\mathbb{R}$ ។

គណនា $f(2015)$ ។

ដំណោះស្រាយ

គណនា $f(2015)$

យើងមាន: $f\left(x^2+x+3\right)+2f\left(x^2-3x+5\right)=6x^2-10x+7\ \ (1)$

ជំនួស x ដោយ $1-x$ ក្នុង (1) យើងបាន:

$f\left(x^2-3x+5\right)+2f\left(x^2+x+3\right)=6x^2-2x+13\ \ (2)$

គុណអង្គទាំងពីរនៃ (2) នឹង -2 គេបាន:

$-2f\left(x^2-3x+5\right)-4f\left(x^2+x+3\right)=-12x^2+4x-26\ \ (3)$

យក $(1)+(3)$ យើងបាន:

$-3f\left(x^2+x+3\right)=-6x^2-6x-9$

$f\left(x^2+x+3\right)=2\left(x^2+x+3\right)-3$

$f\left(2015\right)=2\times 2015-3=4027$

ដូចនេះ $f\left(2015\right)=4027$ ។

លំហាត់ទី៣៨

កំណត់អនុគមន៍ f ដែលកំណត់លើសំណុំចំនួនពិតវិជ្ជមាន ឬ សូន្យ $\mathbb{R}_+$ ទៅ $\mathbb{R}_+$ ហើយផ្ទៀងផ្ទាត់លក្ខខណ្ឌ:

$(i).f(2)=0$

$(ii).f(x)\neq 0 \quad 0\leq x<2$

$(iii).f(x.f(y)).f(y)=f(x+y)$ ចំពោះ $\forall x,y\in\mathbb{R}_+$

ដំណោះស្រាយ

កំណត់អនុគមន៍ f

យើងមាន:

$f:\mathbb{R}_+\rightarrow\mathbb{R}_+$

$(i).f(2)=0$

$(ii).f(x)\neq 0 \quad , \; 0\leq x<2$

$(iii).f(x.f(y)).f(y)=f(x+y) \quad , \; \forall x,y\in\mathbb{R}_+$

-បើ $y=2$ តាម (iii) គេបាន: $f(x.f(2)).f(2)=f(x+2)$

$f(x.0).0=f(x+2)$ ព្រោះ $f(2)=0$

$f(x+2)=0$

តែ $x\geq 0\Rightarrow x+2\geq 2$ គេបាន: $f(x)=0$ ចំពោះ $x\geq 2$

-បើ $x=2-y$ តាម (iii) គេបាន:

$f\left[(2-y).f(y)\right].f(y)=f(2)=0$

$f\left[(2-y).f(y)\right].f(y)=0$ តែ $f(y)\neq 0$ តាម (ii) យើងបាន:

$(2-y).f(y)=2$

$f(y)=\dfrac{2}{2-y}$ ចំពោះ $y<2$

នោះ $f(x)=\dfrac{2}{2-x}$ ចំពោះ $x<2$

ដូចនេះ $f(x)=\begin{cases}\dfrac{2}{2-x} & , \ 0\leq x<2\\ 0 & , \ x\geq 2\end{cases}$

លំហាត់ទី៣៩

ត្រីកោណ ABC មានជ្រុង $BC=x$, $AC=y$ និង $AB=z$ ។

រកតម្លៃតូចបំផុត $S=\sqrt{\dfrac{x}{2y+2z-x}}+\sqrt{\dfrac{y}{2z+2x-y}}+\sqrt{\dfrac{z}{2x+2y-z}}$

ដំណោះស្រាយ

រកតម្លៃតូចបំផុត $S=\sqrt{\dfrac{x}{2y+2z-x}}+\sqrt{\dfrac{y}{2z+2x-y}}+\sqrt{\dfrac{z}{2x+2y-z}}$

យើងមាន: $S=\sqrt{\dfrac{x}{2y+2z-x}}+\sqrt{\dfrac{y}{2z+2x-y}}+\sqrt{\dfrac{z}{2x+2y-z}}$

$=\sqrt{3}\left[\dfrac{x}{\sqrt{3x(2y+2z-x)}}+\dfrac{y}{\sqrt{3y(2z+2x-y)}}+\dfrac{z}{\sqrt{3z(2x+2y-z)}}\right]$

តាមវិសមភាព *Cauchy* គេបាន:

$2(x+y+z)=3x+\left(2y+2z-x\right)\geq 2\sqrt{3x(2y+2z-x)}$

$x+y+z\geq\sqrt{3x(2y+2z-x)}$

$$\frac{x}{\sqrt{3x(2y+2z-x)}} \ge \frac{x}{x+y+z} \quad (1)$$

ស្រាយដូចគ្នាយើងបាន: $\frac{y}{\sqrt{3y(2z+2x-y)}} \ge \frac{y}{x+y+z}$ (2)

$$\frac{z}{\sqrt{3z(2x+2y-z)}} \ge \frac{z}{x+y+z} \quad (3)$$

យក $(1)+(2)+(3)$ រួចគុណនឹង $\sqrt{3}$ យើងបាន:

$S \ge \sqrt{3}\left(\frac{x+y+z}{x+y+z}\right) = \sqrt{3}$ សមភាពកើតមានពេលណា $x=y=z$ ។

ដូចនេះតម្លៃតូចបំផុតនៃ S គឺ $\sqrt{3}$ ។

លំហាត់ទី៤០

ស្រាយថា: $\sqrt[3]{\cos\frac{2\pi}{7}} + \sqrt[3]{\cos\frac{4\pi}{7}} + \sqrt[3]{\cos\frac{6\pi}{7}} = \sqrt[3]{\frac{1}{2}\left(5-3\sqrt[3]{7}\right)}$

ដំណោះស្រាយ

ស្រាយថា: $\sqrt[3]{\cos\frac{2\pi}{7}} + \sqrt[3]{\cos\frac{4\pi}{7}} + \sqrt[3]{\cos\frac{6\pi}{7}} = \sqrt[3]{\frac{1}{2}\left(5-3\sqrt[3]{7}\right)}$

យើងឃើញថា $\frac{2\pi}{7}, \frac{4\pi}{7}, \frac{6\pi}{7}$ ជាឫសនៃសមីការ $3x+4x=2k\pi$

យើងបាន: $\cos 3x = \cos 4x$

$$4\cos^3 x - 3\cos x = 8\cos^4 x - 8\cos^2 x + 1$$

$$(\cos x - 1)\left(8\cos^3 x + 4\cos^2 x - 4\cos x - 1\right) = 0$$

ដោយ $\cos x - 1 \ne 0$ គេបាន: $8\cos^3 x + 4\cos^2 x - 4\cos x - 1 = 0$

យក $t_1 = 2\cos\frac{2\pi}{7}$, $t_2 = 2\cos\frac{4\pi}{7}$, $t_3 = 2\cos\frac{6\pi}{7}$ នោះ t_1 , t_2 , t_3

ជាឫសនៃសមីការ $t^3 + t^2 - 2t - 1 = 0$

ដែល $\begin{cases} t_1+t_2+t_3=-1 \\ t_1t_2+t_2t_3+t_3t_1=-2 \\ t_1t_2t_3=1 \end{cases}$

តាង $A=\sqrt[3]{t_1}+\sqrt[3]{t_2}+\sqrt[3]{t_3}$; $B=\sqrt[3]{t_1t_2}+\sqrt[3]{t_2t_3}+\sqrt[3]{t_3t_1}$ យើងបាន:

$A^3=t_1+t_2+t_3+3AB-3\sqrt[3]{t_1t_2t_3}=3AB-4\ (*)$

$B^3=t_1t_2+t_2t_3+t_3t_1+3B\sqrt[3]{t_1t_2t_3}.A-3\sqrt[3]{t_1^2t_2^2t_3^2}$

$B^3=3AB-5\ (**)$

យក $(*)\times(**)$ គេបាន:

$(AB)^3=9(AB)^2-27AB+20$

$(AB-3)^3+7=0$

$AB=3-\sqrt[3]{7}$

$A^3=5-3\sqrt[3]{7}$

$\Rightarrow A=\sqrt[3]{5-3\sqrt[3]{7}}$

ដូចនេះ $\sqrt[3]{\cos\frac{2\pi}{7}}+\sqrt[3]{\cos\frac{4\pi}{7}}+\sqrt[3]{\cos\frac{6\pi}{7}}=\sqrt[3]{\frac{1}{2}\left(5-3\sqrt[3]{7}\right)}$

អនុវត្តន៍: ស្រាយថា: $\sqrt[3]{\cos\frac{2\pi}{9}}+\sqrt[3]{\cos\frac{4\pi}{9}}+\sqrt[3]{\cos\frac{8\pi}{9}}=\sqrt[3]{\frac{1}{2}\left(3\sqrt[3]{9}-6\right)}$

លំហាត់ទី៤១

គេឲ្យត្រីកោណ ABC មួយចារឹកក្នុងរង្វង់កាំ $R=1$ និងមានជ្រុង $BC=a$, $AC=b$, $AB=c$ ហើយ
មុំ A , B , C បង្កើតបានជាស្វ៊ីតធរណីមាត្រដែលមានផលធៀបរួមស្មើ 2 ។ គណនា $a^2+b^2+c^2$ ។

ដំណោះស្រាយ

គណនា $a^2+b^2+c^2$

តាមទ្រឹស្តីបទស៊ីនុស: $\dfrac{a}{\sin A}=\dfrac{b}{\sin B}=\dfrac{c}{\sin C}=2R$

$\Rightarrow a=2R\sin A\ ,\ b=2R\sin B\ ,\ c=2R\sin C$

យើងបាន: $a^2+b^2+c^2=\left(2R\sin A\right)^2+\left(2R\sin B\right)^2+\left(2R\sin C\right)^2$

$=4R^2\left(\sin^2 A+\sin^2 B+\sin^2 C\right)$

$=4\left(\sin^2 A+\sin^2 B+\sin^2 C\right)\quad ,\ R=1$

ដោយ $A\ ,\ B\ ,\ C$ ជាស្វីតធរណីមាត្រដែលមានរេសុង $q=2$

នោះ: $B=2A\ ,\ C=4A$

តែ $A+B+C=\pi\Rightarrow A+2A+4A=7A=\pi\Rightarrow A=\dfrac{\pi}{7}$

គេបាន: $a^2+b^2+c^2=4\left(\sin^2\dfrac{\pi}{7}+\sin^2\dfrac{2\pi}{7}+\sin^2\dfrac{4\pi}{7}\right)$

$$=4\left[\frac{1}{2}\left(1-\cos\frac{2\pi}{7}+1-\cos\frac{4\pi}{7}+1-\cos\frac{8\pi}{7}\right)\right]$$

$$=2\left[3-\left(\cos\frac{2\pi}{7}+\cos\frac{4\pi}{7}+\cos\frac{8\pi}{7}\right)\right]\quad (*)$$

គណនា $S=\cos\dfrac{2\pi}{7}+\cos\dfrac{4\pi}{7}+\cos\dfrac{6\pi}{7}$

ដោយគុណអង្គនឹង $2\sin\dfrac{\pi}{7}$ យើងបាន:

$$2\sin\frac{\pi}{7}S=2\sin\frac{\pi}{7}\cos\frac{2\pi}{7}+2\sin\frac{\pi}{7}\cos\frac{4\pi}{7}+2\sin\frac{\pi}{7}\cos\frac{8\pi}{7}$$

$$=\left(\sin\frac{3\pi}{7}-\sin\frac{\pi}{7}\right)+\left(\sin\frac{5\pi}{7}-\sin\frac{3\pi}{7}\right)+\left(\sin\frac{9\pi}{7}-\sin\pi\right)$$

$$=\sin\frac{5\pi}{7}+\sin\frac{9\pi}{7}-\sin\frac{\pi}{7}$$

$$= 2\sin\pi.\cos\left(\frac{\frac{9\pi}{7}-\frac{5\pi}{7}}{2}\right)-\sin\frac{\pi}{7} = -\sin\frac{\pi}{7}$$

$$\Rightarrow S = \frac{-\sin\frac{\pi}{7}}{2\sin\frac{\pi}{7}} = -\frac{1}{2}$$

តាម (*) គេបាន: $a^2+b^2+c^2 = 2\left(3+\frac{1}{2}\right) = 7$

ដូចនេះ $a^2+b^2+c^2 = 7$ ។

លំហាត់ទី៤២

A និង B ជាចំនួនគត់វិជ្ជមានដែល:

$$\frac{A}{B} = 1-\frac{1}{2}+\frac{1}{3}-\frac{1}{4}+\cdots-\frac{1}{1342}+\frac{1}{1343}$$ ។

បង្ហាញថា A ចែកដាច់នឹង 2015 ។

ដំណោះស្រាយ

បង្ហាញថា A ចែកដាច់នឹង 2015

យើងមាន: $\frac{A}{B} = 1-\frac{1}{2}+\frac{1}{3}-\frac{1}{4}+\cdots-\frac{1}{1342}+\frac{1}{1343}$

$$= \left(1+\frac{1}{2}+\frac{1}{3}+\cdots+\frac{1}{1343}\right)-2\left(\frac{1}{2}+\frac{1}{4}+\cdots+\frac{1}{1342}\right)$$

$$= \left(1+\frac{1}{2}+\frac{1}{3}+\cdots+\frac{1}{1343}\right)-\left(1+\frac{1}{2}+\cdots+\frac{1}{671}\right)$$

$$= \frac{1}{672}+\frac{1}{673}+\cdots+\frac{1}{1342}+\frac{1}{1343}$$

$$=\left(\frac{1}{672}+\frac{1}{1343}\right)+\left(\frac{1}{673}+\frac{1}{1342}\right)+\cdots$$

$$=\frac{2015}{672\times1343}+\frac{2015}{673\times1342}+\cdots$$

ដូចនេះ A ចែកដាច់នឹង 2015 ។

លំហាត់ទី៤៣

កំណត់ចំនួនថេរ k ដែលពហុធា: $P(x,y,z)=x^5+y^5+z^5+k\left(x^3+y^3+z^3\right)\left(x^2+y^2+z^2\right)$ មានជាកត្តា $x+y+z$ ។ ស្រាយថាចំពោះតម្លៃ k ដែលរកឃើញនេះពហុធា $P(x,y,z)$ មានជាកត្តា $(x+y+z)^2$ ។

ដំណោះស្រាយ

កំណត់ចំនួនថេរ k

សន្មតថា ជាចំនួនថេរ និង ជាអញ្ញាត

បើ $x+y+z$ ឬ $x-(-y-z)$ ជាកត្តានៃ $P(x,y,z)$ កាលណា

$P(-y-z,y,z)=0$

យើងមាន: $P(x,y,z)=x^5+y^5+z^5+k\left(x^3+y^3+z^3\right)\left(x^2+y^2+z^2\right)$

យើងបាន: $P(-y-z,y,z)$

$$=(-y-z)^5+y^5+z^5+k\left[(-y-z)^3+y^3+z^3\right]\left[(-y-z)^2+y^2+z^2\right]=0$$

$$\Leftrightarrow -\left(y^5+5y^4z+10y^3z^2+10y^2z^3+5yz^4+z^5\right)+y^5+z^5$$

$$+k\left(-3y^2z-3yz^2\right)\left(2y^2+2z^2+2yz\right)=0$$

$$\Leftrightarrow -5yz\left(y^3+2y^2z+2yz^2+z^3\right)-6kyz\left(y+z\right)\left(y^2+z^2+yz\right)=0$$

$$\Leftrightarrow -5yz\left[(y+z)\left(y^2-yz+z^2\right)+2yz(y+z)\right]$$

$$-6kyz(y+z)\left(y^2+z^2+yz\right)=0$$

$$\Leftrightarrow -5yz(y+z)\left(y^2+yz+z^2\right)-6kyz(y+z)\left(y^2+yz+z^2\right)=0$$

$$\Leftrightarrow -(5+6k)=0$$

$$\Rightarrow k=-\frac{5}{6}$$

ដូចនេះ $k=-\dfrac{5}{6}$ ។

ស្រាយថាពហុធា $P(x,y,z)$ មានជាកត្តា $(x+y+z)^2$ ចំពោះ $k=-\dfrac{5}{6}$

ចំពោះ $k=-\dfrac{5}{6}$ គេបាន:

$$P(x,y,z)=x^5+y^5+z^5-\frac{5}{6}\left(x^3+y^3+z^3\right)\left(x^2+y^2+z^2\right)$$

$$\Leftrightarrow P(x,y,z)=\frac{1}{6}\left[6\left(x^5+y^5+z^5\right)-5\left(x^3+y^3+z^3\right)\left(x^2+y^2+z^2\right)\right]\ (*)$$

យក x,y,z ជាឫសនៃសមីការ $t^3-at^2+bt-c=0$

ដែលមាន $a=x+y+z$, $b=xy+yz+xz$, $c=xyz$

យើងបាន: $$\begin{cases} x^3-ax^2+bx-c=0 \\ y^3-ay^2+by-c=0 \\ z^3-az^2+bz-c=0 \end{cases} \Leftrightarrow \begin{cases} x^{n+3}-ax^{n+2}+bx^{n+1}-cx^n=0 \\ y^{n+3}-ax^{n+2}+bx^{n+1}-cx^n=0 \\ z^{n+3}-ax^{n+2}+bx^{n+1}-cx^n=0 \end{cases}$$

បូកអង្គ នឹងអង្គរួចតាង $S_n=x^n+y^n+z^n$ គេបាន:

$$S_{n+3}-aS_{n+2}+bS_{n+1}-cS_n=0$$

$$S_{n+3}=aS_{n+2}-bS_{n+1}+cS_n$$

ដោយ $S_0=x^0+y^0+z^0=3$

$$S_1=x+y+z=a$$

$$S_2=x^2+y^2+z^2=(x+y+z)^2-2(xy+yz+zx)=a^2-2b$$

$$S_3 = aS_2 - bS_1 + cS_0$$
$$= a\left(a^2 - 2b\right) - ba + 3c$$
$$= a^3 - 3ab + 3c$$
$$S_4 = aS_3 - bS_2 + cS_1$$
$$= a\left(a^3 - 3ab + 3c\right) - b\left(a^2 - 2b\right) + ca$$
$$= a^4 - 4a^2b + 4ac + 2b^2$$
$$S_5 = aS_4 - bS_3 + cS_2$$
$$= a\left(a^4 - 4a^2b + 4ac + 2b^2\right) - b\left(a^3 - 3ab + 3c\right) + c\left(a^2 - 2b\right)$$
$$= a^5 - 5a^3b + 5a^2c + 5ab^2 - 5bc$$

